CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែឧសភា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០២

## ពលរដ្ឋរអ៊ូរទាំយ៉ាងរឿងស្ថានភាពចរាចរណ៍នៅរាជធានីភ្នំពេញបច្ចុប្បន្ន




CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ទិវានៃការត្រាស់ហៅលើកទី៥៤នៃព្រះសហគមន៍កាតូលិកកម្ពុជា




យុវជន យុវនារី ជាង២៥០នាក់មកពីបណ្ដាព្រះសហគមន៍នានា ក្នុងភូមិភាគទាំងបី បានជួបជុំគ្នាក្នុងទិវានៃការត្រាស់ហៅលើកទី៥៤ នៅព្រះវិហារសន្តប៉ូលសន្តសិលា នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី។

ទិវានេះបានប្រារព្ធទៅ កាលពីថ្ងៃទី៦ ដល់ថ្ងៃទី៧ ឧសភា ២០១៧នេះ ដើម្បីរិះគិតអំពីអនាគតនៃជីវិតរបស់ខ្លួន និងការឆ្លើយតបចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតជាបព្វជិតបព្វជិតា ដែលរៀបចំដោយ គណៈកម្មការអន្តរភូមិភាគសម្រាប់ការត្រាស់ហៅ និងមានលោកអភិបាលអូលីវីយេ ឆ្មឹតអឺស្លែរជាអធិបតី។

នៅក្នុងពេលអភិបូជា លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ទៅកាន់យុវជនយុវនារី និងគ្រីស្តបរិស័ទទាំងអស់ថា ព្រះសហគមន៍កាតូលិកទូទាំងពិភពលោក គោរពទិវានៃការត្រាស់ហៅលើកទី៥៤ គឺជាកាសដើម្បីអធិដ្ឋានឲ្យយុវជនយុវនារី ត្រៀមខ្លួនចូលក្នុងការត្រាស់ហៅ ដោយចែករំលែកអំណរសប្បាយនៃជីវិតរបស់យើងទៅដល់បងប្អូនឯទៀតៗ ដូចដែលសម្ដេចប៉ាប់ បានសសេរនៅក្នុងសៀវភៅចែករំលែកអំណរសប្បាយ។ លោកបានមានប្រសាសន៍បន្តថា សូមឲ្យយើងរកឃើញនូវអំណរសប្បាយនៃជីវិត គឺព្រះយេស៊ូផ្ទាល់ ដែលជាគង្វាលដ៏សប្បុរស។

ក្នុងធម្មទសនា លោកអភិបាលភូមិភាគភ្នំពេញបានរំឭកដល់អ្នកចូលរួមទាំងអស់ថា ពេលយើងនឹកដល់បូជាចារ្យជាច្រើនក្រុមបងស្រី និងគ្រហស្ថជាសាសនទូតសរុប១៩៤នាក់ គឺសុទ្ធតែជាក្រុមសាសនទូត។ លោកថា "ហេតុអ្វីបានជាយើងត្រូវការយុវជនយុវនារី ឆ្លើយតបទៅចំពោះការត្រាស់ហៅបន្ថែមទៀត?" លោកបន្តថា បើធៀបជាមួយនឹងចំនួនគ្រីស្តបរិស័ទជាងពីរម៉ឺននាក់តិចតួច នៅក្នុងប្រទេសកម្ពុជា យើងមានបូជាចារ្យដែលកើតចេញពីទីនេះតែ៩នាក់ប៉ុណ្ណោះ។

លោកបន្ថែមថា "ខ្ញុំទន្ទឹងរង់ចាំជួយដើម្បីឲ្យព្រះសហគមន៍ចាក់ឫសយ៉ាងជ្រៅនៅក្នុងទឹកដីកម្ពុជា"។ លោកអូលីវីយេ ក៏បានស្នើដល់យុវជន យុវនារីទាំងអស់ឲ្យអធិដ្ឋាន ដោយសម្លឹងមើលព្រះយេស៊ូ ដើម្បីស្ដាប់ព្រះសូរសៀង និងចូលនៅក្នុងទំនាក់ទំនងយ៉ាងជ្រៅជាមួយព្រះយេស៊ូដែលជាមិត្តសម្លាញ់។

ក្រោយពីធម្មទេសនាហានបញ្ចប់បងស្រី ព្រុំ សុភី ជាបងស្រីតែម្នាក់គត់នៃអ្នកបម្រើព្រះយេស៊ូ បានបង្កើតឡើងដោយលោកអភិបាល អូលីវីយេ សម្រាប់ភូមិភាគភ្នំពេញ។ សព្វដូនជីរូបនេះបម្រើការនៅក្នុងមណ្ឌលភូមិសុខសាន្ត ជាកន្លែងស្វាគមន៍ កុមារពិការ ធ្ងន់ពិការសតិបញ្ញា និងជាភូមិដែលមានបងប្អូនផ្ទុក និងអ្នកជំងឺអេដស៍រស់នៅ។

ដូនជីព្រុំ សុភីបានចែករំលែកអំពីអំណរសប្បាយនៅក្នុងជីវិតជាដូនជីថា ស្នាមញញឹមរបស់បងប្អូនបានធ្វើឲ្យបងស្រីមានអំណរ ទោះបីជាគ្មានសមាជិក តែរបៀបរស់នៅជាមួយអ្នកភូមិសុខសាន្ត និងរបៀបនៃការបម្រើបងប្អូនឯទៀតៗ ពិតជាធ្វើឲ្យដូនជីរូបនេះមានអំណរសប្បាយនៅក្នុងជីវិតជាអ្នកបួស ដោយមានព្រះជាម្ចាស់គង់នៅជាមួយ។

លើសពីនេះទៅទៀត បងស្រីបានផ្ដាំទៅកាន់យុវជនទាំងអស់ថា តាមពិតព្រះជាម្ចាស់ត្រាស់ហៅយើងគ្រប់ពេលវេលា ហើយយើងក៏អាចឆ្លើយតបទៅព្រះអង្គវិញបានប្រសិនបើយើងចង់។ នៅក្នុងឱកាសនេះដែរ បងស្រីសុភី ក៏បានប្រកាសពាក្យសច្ចារបស់ខ្លួនឡើងវិញ សម្រាប់រយៈមួយឆ្នាំ ដែលតែងតែធ្វើឡើងជារៀងរាល់ឆ្នាំ។ នេះជាឆ្នាំទី៤របស់បងស្រី ដោយស្ម័គ្រចិត្តរស់នៅតាមព្រហ្មចារីធម៌ ជាអ្នកក្រីក្រ និងស្ដាប់បង្គាប់លោកអភិបាល នៅចំពោះមុខឈើឆ្កាង និងគ្រីស្តបរិស័ទទាំងអស់ផងដែរ។

បន្ទាប់ការជួបជុំបានបន្តជួយយុវជនរិះគិត អំពីជីវិតរបស់អ្នកបួស ដោយមានសក្ខីភាព ពីលោកបូជាចារ្យសែ សាត និងមានសំណួរចម្លើយផ្សេងៗ ដែលទាក់ទងនឹងរបៀបរស់នៅ និងប្រវត្តិការត្រាស់ហៅរបស់លោកបូជាចារ្យ និងដូនជី ដែលមានវត្តមានក្នុងអង្គប្រជុំ។

ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានយកចិត្តទុកដាក់ជួយយុវជនក្នុងការរិះគិតអំពីជំនឿ ការត្រាស់ហៅ ដែលមានក្រុមអេម៉ានូអែល ក្រុមសាម៉ូអែល និងក្រុមដំណឹងល្អជាដើម។ *ដោយ ដាលីស*




*វេទិកាសំនួរចម្លើយ ក្នុងកម្មវិធី ទិវានៃការត្រាស់ហៅលើកទី៥៤*

# សូមស្មារតីមន្ទីរពេទ្យគន្ធបុប្ផាមានដល់គ្រប់មន្ទីរពេទ្យនៅកម្ពុជា

រហូតមកដល់ពេលនេះសប្បុរសជនដែលបានគាំទ្រដល់ស្មារតីនិងប្រតិបត្តិការរបស់មន្ទីរ ពេទ្យកុមារគន្ធបុប្ផា គឺកាន់តែមានច្រើន ជាពិសេសសប្បុរសជនជាតិ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើស្មារតីនេះអាចជ្រួតជ្រាបទៅដល់មន្ទីរពេទ្យផ្សេងៗនៅក្នុងប្រទេសកម្ពុជា នោះវារិតតែប្រសើរថែមទៀត។

រហូតមកដល់ពេលនេះ ដោយសារតែប្រតិបត្តិការផ្នែកសប្បុរសធម៌របស់ស្ថាបនិកនៃមន្ទីពេទ្យនេះ មានកុមារកម្ពុជារាប់សិបម៉ឺននាក់ដែលបានទទួលការព្យាបាលសង្គ្រោះជីវិត ដោយមន្ទីរពេទ្យនេះ ដោយមិនប្រកាន់វណ្ណៈ ពណ៌សំបុរ ជាតិសាសន៍ ហើយជាពិសេសគឺ ព្យាបាលដោយមិនគិតថ្លៃ។

ទន្ទឹមនឹងចូលរួមអបអរជាមួយស្មារតីនេះ យើងខ្ញុំក៏សូមចូលរួមអបអរនិងថ្លែងអំណរគុណ ចំពោះសប្បុរសជនជាតិនិងអន្តរជាតិដែលកន្លងមកបានគាំទ្រដល់ប្រតិបត្តិការរបស់មន្ទីរពេទ្យគន្ធបុប្ផា ដោយបង្កើតជាមូលនិធិផ្សេងៗតាមលទ្ធភាពនិងសមត្ថភាព។ ជាពិសេស គឺថ្នាក់ ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា ផ្ទាល់។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលកម្ពុជាតែងតែបង្ហាញពីការគាំទ្រ ដល់ប្រតិបត្តិការរបស់មន្ទីពេទ្យគន្ធបុប្ផា តាមរយៈមូលនិធិ និងសកម្មភាពគៀងគរថវិការផ្សេងៗសម្រាប់មន្ទីពេទ្យនេះ នៅក្នុងនោះកាលពីថ្ងៃទី៨ ខែឧសភាថ្មីៗនេះនៅក្នុងចំណោមទឹកប្រាក់ដែលប្រមូលបានពីសប្បុរសជនជាតិនិងអន្តរជាតិនាថ្ងៃខួប លើកទី១៥៤ នៃកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមអន្តរជាតិ ចំនួនប្រមាណជាជាង១៣,៤ លានដុល្លារ គឺកាកបាទក្រហមបាន សម្រេចភ្លាមៗបរិច្ចាកបន្តនូវទឹកប្រាក់១ លានដុល្លារដល់មន្ទីពេទ្យនេះ។ ប្រមុខរាជរដ្ឋាភិបាលក៏បានប្រកាសជាផ្លូវការដែរថានឹងគាំទ្រមន្ទីពេទ្យនេះមិនឲ្យរលំឡើយ ស្របពេលដែលស្ថាបនិក មន្ទីពេទ្យគន្ធបុប្ផា លោកប៊ីត រីចណាន័រ កំពុងមានបញ្ហាសុខភាព និងវ័យកាន់តែចាស់ទៅៗ។

ដោយសារតែស្មារតីនេះហើយ មន្ទីពេទ្យគន្ធបុប្ផាក្នុងរយៈពេលថ្មីៗនេះ បានទទួលការចូលរួមជាមូលនិធិច្រើន ពីមហាជនដោយរួមទាំងសេដ្ឋីនៅក្នុងស្រុកផងដែរ។

ការគាំទ្រជាមូលនិធិបែបនេះគឺដោយសារតែពួកគេជឿជាក់ទៅលើប្រតិបត្តិការមនុស្សធម៌ របស់មន្ទីពេទ្យ ដែលបានជួយប្រទេសកម្ពុជាលើការព្យាបាលជំងឺដល់កុមារជាច្រើនឆ្នាំកន្លងមក។ ជារៀងរាល់ថ្ងៃកុមារមកពីគ្រប់ខេត្ត ក្រុង ស្រុក ខ័ណ្ឌមករកសេវាព្យាបាលជំងឺ និងសង្គ្រោះជីវិតនៅមន្ទីរពេទ្យនេះរាប់រយនាក់ បើទោបីជានៅពេលនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិត ខំពង្រាយសេវាសុខាភិបាលកាន់តែច្រើនក្តី។

ដោយដឹងថា សេវាសុខភាពជាវិស័យដ៏សំខាន់ នៅក្នុងការគាំពារសុខភាពរបស់ប្រជាពលរដ្ឋរាជរដ្ឋាភិបាលបានចាត់ទុកវិស័យសុខាភិបាលជាវិស័យដ៏អតិភាពមួយ ដោយនៅក្នុងនោះនៅតាមខេត្តនីមួយៗមានមន្ទីពេទ្យថ្នាក់ខេត្ត តាមស្រុក ហើយកំពុងតែយកចិត្តទុកដាក់បង្កើតមណ្ឌលសុខភាពនៅតាមមូលដ្ឋាន ពោលគឺតាមឃុំថែម ទៀត ប៉ុន្តែភាគច្រើនប្រជាពលរដ្ឋនៅតែសុខចិត្តធ្វើដំណើររាប់សិបគីឡូ ចំណាយពេលរាប់ម៉ោងមកកាន់មន្ទីពេទ្យគន្ធបុប្ផាទាំងនៅភ្នំពេញ និងនៅខេត្តសៀមរាបនោះហើយ ដែលយើងគួរតែគិតស្វែងរកមូលហេតុដើម្បីដំណោះស្រាយ។ តើហេតុអ្វី?

យើងដឹងថា វិស័យសុខាភិបាលស្រុកយើងនៅមានបញ្ហាប្រឈមសំខាន់គឺ រឿងក្រមសីលធម៌របស់ក្រុមគ្រូពេទ្យ ប៉ុន្តែក្រោយការស្តីបន្ទោស និងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល បញ្ហាក្រមសីលធម៌នេះ ហាក់មានការកែលំអរទៅតាមកម្រិតមន្ទីពេទ្យធំៗនៅក្នុងប្រទេស បើទោះបីជាវាអាចប្រឈមខ្លះនៅតាមមូលដ្ឋាន តែនេះអាចជាបច្ច័យមួយ។ ក្រៅពីនោះ សមត្ថភាពគ្រូពេទ្យជំនាញក៏គួរតែយកចិត្តទុកដាក់ផងដែរ ក្រៅពីនេះ បញ្ហាបរិក្ខារពេទ្យ បញ្ហាប្រាក់បៀវត្សរ៍ និងថ្នាំសង្ស័យក៏ជារឿងសំខាន់ជាដើម។

សរុបមកវិញយើងដឹងថា ការជំរុញឲ្យមន្ទីពេទ្យទាំងអស់ប្រកាន់យកតាមស្មារតីមនុស្សធម៌ និងប្រតិបត្តិការសេវាសុខភាពដូចជាមន្ទីពេទ្យគន្ធបុប្ផាទាំងអស់មិនមែនជារឿងងាយទេ ប៉ុន្តែប្រសិនបើយើងមានឆន្ទៈ យើងរំពឹងថា យើងអាចកែលំអរបន្តិចម្តងៗដើម្បីឲ្យសេវាសុខភាពសាធារណៈនៃកម្ពុជា អាចឈានដល់ចំណុចទាំងនេះ នោះពលរដ្ឋកាន់តែមានភាពកក់ក្តៅ និងសេវាកម្មនេះនៅក្នុងប្រទេស។

# អធិដ្ឋានសម្រាប់ការត្រាស់ហៅលើកទី៦០

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅលើកទី៦០ នៅក្នុងមណ្ឌលសកម្មភាពតាខ្មៅ ដើម្បីទូលសូមអង្វរព្រះជាម្ចាស់ឲ្យមានយុវជនយុវនារីស្ម័គ្រចិត្តថ្វាយខ្លួន ជាបព្វជិត បព្វជិតា កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧កន្លងទៅនេះ។

កម្មវិធីអធិដ្ឋាននេះបានរៀបចំឡើង ក្រោមការដឹកនាំរបស់លោកអភិបាលអូលីវីយេ ជ្មីតអឺស្លែរ និងលោកបូជាចារ្យម៉ារីយ៉ូ ហ្គេហ្ស៊ី ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតាខ្មៅ ដោយមានគ្រីស្តបរិស័ទ និងបងប្អូនដែលចង់ស្គាល់ព្រះជាម្ចាស់បានចូលរួមជាច្រើននាក់ផងដែរ។

ជាកិច្ចចាប់ផ្តើមអភិបូជា លោកបូជាទទួលខុសត្រូវមណ្ឌលសកម្មភាព បានមានប្រសាសន៍ស្វាគមន៍បងប្អូនទាំងអស់ និងសង្ឃឹមថាក្រោយពីកម្មវិធីអធិដ្ឋានយប់នេះ នឹងមានយុវជនយុវនារី ចាប់អារម្មណ៍ចូលទៅវិទ្យាល័យ ឬក្រុមគ្រួសារដូនជីណាមួយ។



ថតដោយ លី សុវណ្ណា

រីឯលោកអភិបាលអូលីវីយេ បានសូមអង្វរព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីលើកទឹកចិត្ត និងជំរុញយុវជននឹងយុវនារីឲ្យក្លាយទៅជាអ្នកប្រកាសដំណឹងល្អដ៏ល្អ។

នៅក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ក្រើនរំឭកទៅកាន់គ្រីស្តបរិស័ទទាំងអស់ថា "តួនាទីមួយពិសេសដែលយើងទទួលជាគ្រីស្តបរិស័ទ គឺណែនាំឲ្យគេបានស្គាល់ និងយល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់មានន័យដូចម្តេច?"។

លោកបន្ថែមថា "យប់នេះយើងអធិដ្ឋានរបៀបពិសេស ដើម្បីគិតថា តើព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើអ្វីខ្លះ ដើម្បីជួយអ្នកដទៃ ជួយសាលារៀន និងជួយពិភពលោកនេះ?

លើសពីនេះ លោកអូលីវីយេ បានលើកឡើងថា ព្រះយេស៊ូយាងមកដើម្បីណែនាំ និងចិញ្ចឹមជីវិតរបស់យើង ដោយទ្រង់ទន្ទឹងរង់ចាំឲ្យយើងរកឃើញម្ហូបអាហារនៃវិញ្ញាណ ដែលធ្វើឲ្យជីវិតមានក្តីសុខ និងអំណរសប្បាយ តាមរបៀបបង្កើតទំនាក់ទំនងជាមួយមនុស្សឯទៀតៗ។

ក្រោយអភិបូជា ព្រះសហគមន៍បានរៀបចំកម្មវិធីអធិដ្ឋាននមស្ការព្រះកាយព្រះគ្រីស្តតាមវេណរៀងៗខ្លួនពេញមួយយប់។

ព្រះសហគមន៍ភូមិភាគភ្នំពេញតែងតែប្រារព្ធកម្មវិធីនេះ រៀងរាល់ថ្ងៃព្រហស្បតិ៍ ក្នុងសប្តាហ៍ទីមួយនៃខែនីមួយៗ ដោយផ្លាស់ប្តូរទីតាំងតាមមណ្ឌលសកម្មភាពនៃភូមិភាគភ្នំពេញ។ តាមរយៈការអធិដ្ឋាននេះដែរ ព្រះសហគមន៍បច្ចុប្បន្នបានឃើញថា មានយុវជនយុវនារីបានចាប់អារម្មណ៍ចំពោះជីវិតជាបព្វជិត បព្វជិតា ដោយមានយុវជនបានស្នើសុំចុះឈ្មោះចូលក្រុមសន្តមីកាអែលដើម្បីរិះគិតត្រៀមខ្លួន ចូលទៅវិទ្យាល័យ និងចូលក្រុមអេម៉ាណូអែល និងចូលក្រុមសាម៉ូអែល ព្រមទាំងចូលក្រុមដូនជីកាតូលិកជាដើម។

*ដោយដាលីស*

# កសិករកម្ពុជានៅក្រៅរង្វង់ទីផ្សារបន្លែស្វែងរកទីផ្សារលក់

សព្វថ្ងៃនេះបើនិយាយអំពីទីតាំងសម្រាប់ដាំដំណាំផលិតផលបន្លែ គឺប្រជាពលរដ្ឋកម្ពុជាភាគច្រើន គឺសំដៅទៅរកទីតាំងនៅតាមបណ្ដោយដងទន្លេ មានដូចជាទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងដងទន្លេបាសាក់ជាដើម ប៉ុន្តែក្រៅពីតំបន់នោះ គឺភាគច្រើនប្រជាពលរដ្ឋមិនសូវជាចាប់អារម្មណ៍។

លោក សាញ់ យុត្តារិទ្ធ ជាកសិករមួយរូបនៅស្រុកដងទង់ ខេត្តកំពត បានមានប្រសាសន៍នៅលើ រថយន្តក្រុងភ្នំពេញ-កំពតកាលពីពេលថ្មីៗនេះថា បើនិយាយអំពីដំណាំបន្លែ គឺលោកនិងគ្រួសារអាចមានសមត្ថភាពដាំបានជាច្រើនមុខ ប៉ុន្តែលោកមិនមានទីផ្សារធំក្រៅពីទីផ្សារនៅក្នុងមូលដ្ឋាន ដែលមានតម្លៃថោក និងទំហំតិចតួច។

លោកបានរៀបរាប់ថា លោកអាចដាំដំណាំដូចជា ប្រភេទស្ពៃមានស្ពៃខ្មៅ ស្ពៃជើងទា ស្ពៃក្ដោប ម្ទេស ខាត់ណា ត្រប់ជាច្រើនប្រភេទ ល្ពៅ ជាដើម ប៉ុន្តែវាមិនមានទីផ្សារធំដំក្រៅពីលក់នៅក្នុង ស្រុកភូមិ និងអ្នកជិតខាងឡើយ។

លោកបានបន្តទៀតថា នៅលើដីប្រមាណជា២០អា គឺអាចដាំម្ទេស និងប្រភេទបន្លែនោះបានច្រើនគុំច្រើនរងដែរ ប៉ុន្តែដល់ផលិតបាន គឺប្រភេទខ្លះលក់មិនទាន់ នាំឲ្យខូចចោលដោយសារតែទីផ្សារវាតូច ប៉ុន្តែដល់តែឃើងហៅឈ្មួញបន្លែគេចុះមកទិញទៅលក់នៅភ្នំពេញ គេនិយាយថាវាបែរជាតិចពេកធ្វើឲ្យឈ្មួញគេពិបាកដឹកទៅលក់បន្តនៅទីផ្សារធំ ។

លោកបានបញ្ជាក់ថា "លំបាកដែរបន្លែខ្ញុំអាចកាត់លក់ត្រឹមតែ ៤ទៅ ១០ គីឡូក្រាមទេនៅក្នុង មួយ អាទិត្យ តែបើច្រើនជាងហ្នឹងច្បាស់ជារលួយចោល ហើយបើត្រូវកាត់លក់ឲ្យឈ្មួញធំៗវិញ គឺគេត្រូវការចាប់ពី ១០០ គីឡូអីឯណោះ ចឹងវាធំពេកយើងផលិតវាមិនគ្រប់ឲ្យគេ"។

លោក ខាត់ ណុប ជាកសិករមួយរូបដែលកំពុងតែចងគោ នៅកន្លែងដាំឪឡឹក និងត្រសក់ស្រូវមួយកន្លែង តាមដងផ្លូវជាតិលេខ៣ ហូសផ្សារឈូក ស្រុកឈូក ខេត្តកំពត ក៏បានត្អូញត្អែរអំពី កង្វះខាតទីផ្សារសម្រាប់ដំណាំរួមផ្សំ ដែលកសិករអាចដាំបានក្រោយពីរដូវធ្វើស្រែ។

លោកបាននិយាយថា ក្រៅពីធ្វើស្រែយកអង្ករទុកហូបប្រចាំឆ្នាំ ចំណូលសម្រាប់គ្រួសាររបស់លោក គឺគ្មានអ្វីក្រៅពីលក់ផ្លែដូង និងជួញមាន់ជួញទាបន្តិចបន្តួចគ្រាន់នឹងដោះស្រាយជីវភាព ខណៈដែលរឿងបន្លែដូចជា ត្រសក់ ល្ពៅ ឪឡឹកអីគឺគ្រាន់តែដាំដើម្បីហូប និងចែកបងប្អូនប៉ុណ្ណោះ បើនិយាយថាជាប្រភពចំណូលគឺវាមានតិចតួចពេក។

លោកបានបញ្ជាក់ថា "ស្រុកខ្ញុំនេះក្រៅពីដូង មាន់ ទា ជ្រូក គោ គ្មាននរណាចុះមកទិញស្អីក្រៅពីនោះទេ ដូច្នេះកុំសង្ឃឹមអារឿងដាំបន្លែស្អីនោះ"។

លោកបានបញ្ជាក់បន្ថែមថា "សម្រាប់បន្លែទាំងគាត់និងកសិករឯទៀតនៅក្នុងភូមិ គឺអាចដាំបានឲ្យតែមានទឹកស្រោច ប៉ុន្តែដល់ដាំបានមិនដឹងលក់ឲ្យអ្នកណា ម្នាក់ៗបេះតែខ្ជិល ដេកអេះពោះទំនេរចោលទៅ។

លោកស្រី នឿន សារឿន ជាកសិករវ័យ ៣៨ ឆ្នាំកំពុងតែដើរបេះក្ដឹបឪឡឹកនៅក្បែរនោះដែរបាននិយាយថា លក់ឲ្យនរណានៅទីនោះ ក្រៅពីអ្នកភូមិគាត់មកសុំគ្នាបរិភោគ តែបើអ្នកដែលមានចិត្តអីគេឲ្យ ហុចលុយឲ្យ២០០០ទៅ ៣០០០ទៅ ហើយគេបេះមួយដៃចឹងទៅ។

លោកស្រីបានបន្តថា ដូចឪឡឹកចឹងនៅទីនេះមានអ្នកណាគេទិញ បើបានផលដឹកមិនបានមួយដឹក (មួយរទេះ)ផងនោះ ដូចម្ដុំត្រាំខ្នារគឺវាសំបូរគេដាំច្រើន អីចឹងហើយបានជាមានឈ្មួញគេទិញទៅលក់នៅភ្នំពេញបាន ប៉ុន្តែនៅទីនេះគ្មានអ្នកណាគេទិញទេ។

លោកស្រីបានបញ្ជាក់ថា ឃើញខ្ញុំដើរបេះក្ដឹបឪឡឹកពេលនេះមិនមែនលក់ទេ គឺយកទៅផ្ញើបងប្អូន នៅភ្នំពេញ គេចូលចិត្តយកទៅស្ល គេថាបន្លែអត់គីមីប៉ុណ្ណោះ។ នៅទីនេះដាំបន្លែមិនសូវបានតម្លៃទេ អីចឹងហើយបានជាមិនសូវមានអ្នកដាំ។ ទីនេះច្រើនសុំគ្នាបរិភាគប៉ុណ្ណោះ"។

លោកស្រីបានបន្តថា ក្រៅពីគេសុំ បើយើងបេះទៅលក់នៅផ្សារក្បែរនេះក៏បានដែរ ប៉ុន្តែវាក៏មិនជាច្រើនប៉ុន្មានដែរ គឺ មួយថ្ងៃ បានត្រឹម ៤ទៅ ១០គីឡូប៉ុណ្ណោះ បើច្រើនជាងហ្នឹងគឺមានតែសល់ ប៉ុណ្ណោះ តែវាសំណាងខ្លះដែរបើជួនកាលប៉ះអ្នកភ្នំពេញគេឈប់ឡានទិញអី ជួនកាលអាចកាត់លក់បានលើសនេះខ្លះ។

ជុំវិញបញ្ហានេះ លោក សម បុណ្ណា ជាអ្នកបើកឡានដឹកដូងមួយរូប បានឲ្យដឹងថា លោកបានឲ្យដឹងថា បន្លែមានទីផ្សារធំ ហើយក៏ធ្លាប់មានគំនិតចង់ដឹកត្រសក់ល្ពៅដែលដាំនៅម្ដុំតាកែវកំពតនេះទៅលក់ នៅផ្សារដើមគរដែរ ប៉ុន្តែវាលំបាកប្រមូល ពីព្រោះអ្នកដាំវាតិចប្រមូលមិនគ្រប់ទំងន់ដឹកទៅ ។

លោកបានបន្តថា កាលណាវាតិចមិនគ្រប់តោនវា គឺវាមិនរួចថ្លៃសាំងទេ ហើយបើដើរប្រមូល ភូមិនេះ មួយចុប ភូមិនោះមួយចុបទៀត ក៏មិនរួចថ្លៃសាំងដែរចុះនៅពេលដឹកទៅទៀត បន្លែវាមិនស្វិត មិនស្រពោន។ បន្លែវាខុសពីដូង ដូងអាចដើរសន្សំបាន ដោយសារវាមិនចេះស្វិត ហើយចាប់ពីដី តាកែវកំពតនេះ គឺសំបូរដូងណាស់ផ្ទះណាក៏មានដែរ ចឹងវាមិនចាំបាច់ប្រមូលច្រើនទេ ម្ដងចូលផ្ទះនេះម្ដងចូលផ្ទះនោះឡើងកាប់ពេញឡានដឹកមកភ្នំពេញបាត់។

លោកបានបន្តថា លោកបានធ្លាប់ជួប ហើយអ្នកដឹកបន្លែបោះនៅផ្សារដើមគរនោះ គេនិយាយថា គេមិនលំបាកទេ គេទៅតែមួយជើង ហើយតែមួយកន្លែងគឺគេដឹកបានរាប់សិបគីឡូមកវិញភ្លាម។

លោកបានបញ្ជាក់ថា "ដូចនៅស្អាងអីដល់ខែ ស្ពៃ គឺមួយជើងៗ សុទ្ធតែស្ពៃ ដល់នរណាដឹក ល្ហុង គឺមួយជើងៗសុទ្ធតែល្ហុង ខាត់ណាគឺខាត់ណា ដូច្នេះវាច្រើន។

ជុំវិញបញ្ហាទីផ្សារបន្លែនេះ មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានអះអាងថាទំហំទីផ្សារបន្លែនៅកម្ពុជាមិនតូចទេ គឺប្រមាណជា ០,៩៣ លានតោនឯណោះនៅក្នុងមួយឆ្នាំនៅក្នុងនោះសម្រាប់ទីក្រុងភ្នំពេញ គឺត្រូវការពី ២០០ទៅ ៣០០ តោននៅក្នុងមួយថ្ងៃ នៅក្នុងនោះភាគច្រើនគឺនាំចូល។

លោក ហ៊ាន វណ្ណហ៊ាន អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម បានឲ្យដឹងថា កសិករកម្ពុជាអាចនឹងផ្គត់ផ្គង់ទីផ្សារបន្លែបានត្រឹមតែ ពី ៤៧ភាគរយ ប៉ុណ្ណោះ ក្រៅពីនោះគឺនាំចូលពីប្រទេសជិតខាង។ លោកបានបន្តទៀតថា លទ្ធភាពនេះគឺធានាបានត្រឹមតែពីខែវិច្ឆិកា ដល់ខែមីនា ប៉ុណ្ណោះ ក្រៅពីនោះ គឺនាំចូលដដែល។

លោកបានថ្លែងថា ទាក់ទងនឹងសមត្ថភាពនេះក្រសួងកំពុងតែ ជំរុញកសិករតាមរយៈការលើកទឹកចិត្តចងក្រងពួកគេឲ្យទៅជាសហគមន៍ផលិតបន្លែ ដើម្បីងាយស្រួលចែកចាយបច្ចេកទេស និងប្រមូលទិញ។

យោងទៅតាមរបាយការណ៍មួយរបស់អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ បានឲ្យដឹងថា ទំហំនៃការនាំចូលបន្លែនៅកម្ពុជា គឺមានតួលេខលំអៀងបន្តិចទៀត គឺប្រមាណជា ៥៦ ភាគរយឯណោះ ចំណែកឯសមត្ថភាពផ្គត់ផ្គង់របស់កសិករ គឺត្រឹមតែ ៤៤ភាគរយ។ ប្រទេសដែលនាំចូលបន្លែមកក្នុងទីផ្សារបន្លែនៅកម្ពុជា គឺមានវៀតណាម ថៃ និងចិនជាដើម។

ប្រភេទបន្លែដែលនាំចូលមកក្នុងប្រទេសកម្ពុជា គឺមានទាំងបន្លែដែលកសិករនៅក្នុងប្រទេសអាច ដាំបាន ដែលកន្លងមកគេដឹងថា មានទាំងស្លឹកគ្រៃ ស្លឹកខ្ទឹម ម្ទេសឡើងទៅ។

*ដោយ អរិយបុត្រ*



*ថតដោយ រិទ្ធី*

# យុវជនទាំងនៅជនបទ និងទីក្រុងដឹងអំពីការបោះឆ្នោតខែមិថុនា ប៉ុន្តែមិនសូវចាប់អារម្មណ៍

បណ្តាយុវជនដែលគ្រប់អាយុសម្រាប់បោះឆ្នោតដឹងអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅពេលខាងមុខ ប៉ុន្តែពួកគេហាក់មានអារម្មណ៍សោះអង្គើយនឹងការរៀបចំការបោះឆ្នោតខាងមុខ បើទោះបីជាពេលនេះ គណបក្សធំៗដែលបានចុះឈ្មោះចូលរួមការបោះឆ្នោតកំពុងតែរៀបចំជើងព្រួលរបស់ពួកគេដើម្បីចូលរួមការបោះឆ្នោតនេះនៅខែមិថុនាក៏ដោយ។

ជុំវិញចំណុចនេះយុវជនមួយរូប ដែលកំពុងតែទទួលទានអាហារពេលព្រឹកនៅផ្សារអង់តាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានរៀបរាប់ថា រូបគេបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមកដល់ ពេលនេះមិនដឹងថា ការបោះឆ្នោតនោះប្រព្រឹត្តទៅនៅថ្ងៃណានៅឡើយទេ ។

យុវជនឈ្មោះប្រាក់ វឌ្ឍនា អាយុ ១៩ឆ្នាំ បានឲ្យដឹងថា ខ្លួនបានចុះឈ្មោះរួច ហើយក៏មានឈ្មោះត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោតថែមទៀត ប៉ុន្តែការងារទាំងនេះគឺគាត់មិនដឹងទេ ពីព្រោះមានគេមកប្រាប់។ ទាក់ទងនឹងការបោះឆ្នោតនេះ វឌ្ឍនា បានរៀបរាប់ថា ខ្លួនបានដឹងថានឹងមានការបោះឆ្នោត ហើយក៏ធ្លាប់ឃើញគេទៅបោះឆ្នោតដែរ ប៉ុន្តែមិនដឹងថា ដំណើរការវាយ៉ាងណាទេ ដោយសារតែ មិនដែលបានចូលរួមផ្ទាល់។

វឌ្ឍនា បានបញ្ជាក់ថា "ខ្ញុំដឹងអំពីការបោះឆ្នោត ពីព្រោះធ្លាប់ទៅបោះជាមួយម៉ែជាមួយពុក កាលពី នៅក្មេងៗ តែពេលបោះខ្លួនឯងគឺមិនដែលទេ"។ ទាក់ទងនឹងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នាពេលខាងមុខនេះ វឌ្ឍនា ដឹងនិងឮពេលខាងគណ-បក្សគេចុះមកប្រាប់ចុះមកពន្យល់ ប៉ុន្តែគ្រាន់តែមិនសូវយកចិត្តទុកដាក់គឺចាំដល់ថ្ងៃបោះឆ្នោត ទៅបោះនឹងគេទៅគឺចប់ហើយ។ វឌ្ឍនាបានបញ្ជាក់ថា "ការបោះឆ្នោតនេះ ដូចជាអត់មានអីឲ្យរវល់ (វិលវល់)ទេ គឺដល់ថ្ងៃទៅបោះនឹងគេទៅគឺចប់ហើយ"។

អង្គុយស្រស់ស្រូបនៅក្បែរគ្នានោះ យុវជន ទេព វាសនា អាយុ ២០ឆ្នាំបានឲ្យដឹងថា ខ្លួនក៏បានចុះឈ្មោះរួចហើយដែរ ប៉ុន្តែតាំងពីចុះឈ្មោះរហូតដល់ចេញឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនោះគឺ គាត់មិនដែលរវល់ទេ គឺមានគេជួយសម្រួលគាត់ និងគ្រួសារ។

វាសនា បានបញ្ជាក់ថា "ខ្ញុំមិនចាំទេ កាលពីពេលចុះឈ្មោះ នៅសាលាឃុំ ប៉ុន្តែស្រពេចស្រពិលថា កាលណោះ ពូប្រធានភូមិបានមកប្រាប់ដូចជាពេលចុះពីឡានពេលត្រឡប់មកពីរោងចក្រថា ខ្ញុំត្រូវទៅចុះឈ្មោះបោះឆ្នោត នៅសាលាឃុំ។ ហើយដូចជាយូរដែរ គាត់ក៏បានមកប្រាប់ថា មានឈ្មោះ និងសួរថា ឈ្មោះដែលគាត់សរសេរនេះត្រឹមត្រូវ ឬអត់?"។ ជុំវិញការបោះឆ្នោតនេះ វាសនា បានឲ្យដឹងថា គាត់និងមិត្តភក្តិទាំងនៅភូមិ និងនៅកន្លែងធ្វើការ ដូចជាមិនដែលបាន និយាយគ្នារឿងនេះទេ តែឮចាស់ៗជជែក ប៉ុន្តែគាត់បានអះអាងថា នឹងទៅចូលរួមការបោះឆ្នោតនៅពេលខាងមុខ ក្រោយពេលដែលគេចុះមកប្រាប់ថា ទៅបោះនៅកន្លែងណាពេលណា។ វាសនា បាននិយាយបញ្ជាក់យ៉ាងរំភើយថា "រឿងបោះឆ្នោត រឿងប្រទេសអីនោះ គឺជារឿងរបស់ចាស់ៗនោះទេ"។

តាមការរៀបរាប់របស់យុវជន ទេព វាសនា និងប្រាក់ វឌ្ឍនា នៅពេលទំនេរពីការងារពួកគេ ពិតជាមិនដែលបានជជែកគ្នា អំពីការបោះឆ្នោតនេះមែន ហើយក៏មិនដែលយកចិត្តទុកដាក់នឹងការជជែកគ្នារបស់ចាស់ៗពីរឿងរៀបចំការបោះឆ្នោតនេះដែរ ។ជាទូទៅសាច់រឿងដែលពួកគេនិងមិត្តភក្តិច្រើនតែជជែកគ្នាលេង នៅពេលទំនេរ គឺរឿងសប្បាយៗស៊ីផឹកជប់លៀង រឿងដើរលេង រឿងហ្វេសបុក...។

មិនខុសពីយុវជននៅតំបន់ជនបទនៃប្រទេសនោះទេ យុវជននៅក្នុងទីក្រុងមួយក្រុមក៏ហាក់ដូចជា មិនសូវចាប់អារម្មណ៍នឹងការបោះឆ្នោតនេះខ្លាំងប៉ុន្មានដែរ ដោយពួកគេបានអះអាងថា នេះគឺជារឿងនយោបាយ ហើយពួកគេគឺនៅក្មេង និងនៅឆ្ងាយនៅឡើយពីទីតាំងនយោបាយនោះ។

នៅក្នុងចំណោមយុវជនមួយក្រុមដែលកំពុងតែជជែកគ្នាលេង នៅសួនច្បារសាធារណៈនៅមាត់ទន្លេ កាលពីពេលថ្មីៗនេះ យុវជន ជេត សុវណ្ណដា បាននិយាយថា គាត់បានចុះឈ្មោះបោះឆ្នោតរួចរាល់ហើយ ប៉ុន្តែមិនមែននៅទីក្រុងភ្នំពេញទេ គឺនៅឯកំពង់ចាមជិតស្ពួងត្បូងឃ្មុំឯណោះ ហើយនៅពេលការបោះឆ្នោតមកដល់ ក៏ប្រហែលជានឹងទៅចូលរួមបោះនឹងគេ ប៉ុន្តែនោះគឺប្រហែលជាបោះដើម្បីតែបោះទេ ។

សុវណ្ណដា បានបន្តថា នេះគឺជាការបោះឆ្នោតឃុំ/សង្កាត់ តែរូបគាត់នៅរៀនឯភ្នំពេញ ដូច្នេះវាមិនមានពេល និងឱកាសទៅស្វែងយល់ពីបេក្ខជនដែលឈរឈ្មោះនៅក្នុងឃុំ ឲ្យគ្រប់គណបក្សអស់ដែរ មានតែទុកឲ្យចាស់ៗគ្នាគាត់ទេ ដែលស្គាល់ សម្រាប់ក្មេងៗគឺទៅចេះតែទៅដើម្បីបង្គ្រប់កិច្ច នឹងគេទៅ។

សុវណ្ណដា បានបន្តថា "មនុស្សមួយឃុំច្រើន ក្មេងៗដូចពួកខ្ញុំ បើម៉ាឆ្នាំៗទៅម្តងពីរដង ចាំតែស្គាល់ពួកគាត់អស់តើ អីចឹងមានតែចេះតែបោះចោលៗទៅពេលដល់ថ្ងៃនោះ។ ជុំវិញកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នេះ យុវជនភាគច្រើនដឹងថា នៅខែមិថុនា ប៉ុន្តែពួកគេក៏មិនជាចាំថា នៅថ្ងៃណាឲ្យប្រាកដទេ ដោយពួកគេអះអាងថា អាណាព្យាបាលពួកគេនឹងទូរស័ព្ទប្រាប់ ហើយអ្នកខ្លះ បានអះអាងថា មើលតែបណ្តាញទំនាក់ទំនងសង្គមទៅក៏អាចដឹងដែរ។

សុវណ្ណដាបានបញ្ជាក់ថា "ចាំមើលតែដល់ថ្ងៃ ម៉ែគាត់តែប្រាប់ហើយ ដូចកាលពីពេលចុះឈ្មោះអីចឹង។ ស្រុកយើងឥឡូវវាស្រួលមានរឿងអីទំនាក់ទំនងគ្នាលឿន" ។

យុវជន ធុក លីហៀង បានឲ្យដឹងថា រឿងបោះឆ្នោតនេះ គឺជារឿងមនុស្សចាស់នៅក្នុងសង្គមនោះទេ ដោយឡែកសម្រាប់យុវជន និងយុវនារីដែលកំពុងតែសិក្សាគ្រាន់តែដឹងក៏បាន មិនចាំបាច់ស៊ីជម្រៅ ហើយប្រឡូកទេ។ យុវជនរូបនេះបានបន្តថាគាត់នឹងទៅចូលរួមបោះឆ្នោតនៅពេលខាងមុខនេះទោះបីជាមិនទាន់បានដឹងថា បោះនៅពេលណាក៏ដោយ។ គាត់បានទៅចុះឈ្មោះ ហើយ ប៉ុន្តែនៅពេលដែលសួរថា មានបានទៅពិនិត្យឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទេ មានឬក៏អត់ លី ហៀង បានឆ្លើយថាមិនបានដឹងរឿងនេះផង ដឹងតែរឿងទៅចុះឈ្មោះបោះឆ្នោត ប៉ុន្តែសង្ឃឹមថា ប៉ាឬម៉ាក់របស់គាត់ដឹងហើយ បានជាមិនមានមាត់ករអីរឿងនេះ។ លីហៀងបានបញ្ជាក់ថា "ក្មេងៗដូចពួកខ្ញុំ គឺបានត្រឹមតែចូលរួមឲ្យដឹងៗនឹងគេទៅបានហើយ ពេលប្រឡូកចាំពេលចេញធ្វើការ មានលុយមានកាក់ ចាយខ្លួនឯងចាំគិត"។

តាមការគ្រោងទុកកម្ពុជានឹងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នៅក្នុងថ្ងៃទី០៤ មិថុនា ២០១៧ ខាងមុខនេះ។គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឲ្យដឹងថា មកដល់ពេលនេះ គឺមិនមានគណបក្សនយោបាយចំនួន១២ប្រកាសពីការដាក់បេក្ខភាពប្រជែង យកតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ ឬសង្កាត់នេះ ប៉ុន្តែនៅក្នុងចំណោមគណបក្សទាំង ១២ ដែលបានប្រកាសចូលរួមនោះ គឺមានបេក្ខភាពគ្រប់ឃុំ ឬសង្កាត់ទូទាំងប្រទេសទាំងអស់នោះទេ។ គណបក្សដែលមានបេក្ខភាពសម្រាប់ការបោះឆ្នោតនេះគ្រប់គឺមានតែគណបក្សធំៗប៉ុណ្ណោះ ខណៈគណបក្សតូចៗ គឺមានបេក្ខជនទៅតាមសមត្ថភាព និងធនធានរបស់ពួកគេ។

ម្យ៉ាងវិញទៀតបើតាមគណៈកម្មាការរៀបចំការបោះឆ្នោត ការបោះឆ្នោតខាងមុខនេះ លេខរៀងគណបក្សដែលចូលរួមការបោះឆ្នោត គឺមិនមែនដូចគ្នាដូចការបោះឆ្នោតជាតិនោះទេ គឺវានឹងប្រែប្រួលទៅតាមការចាប់ឆ្នោតនៅតាមឃុំ ឬសង្កាត់ផ្ទាល់។

*ដោយ អរិយបុត្រ*



*ថតដោយ សហការី ស៊ីអេសស៊ី*

# ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ អាលេលូយ៉ា!



*ថតដោយ លី សុវណ្ណា*

គ្រីស្តបរិស័ទមកពីកន្លែងផ្សេងៗ នៃព្រះសហគមន៍កាតូលិកតំបន់ខេត្តតាកែវ បានជួបជុំគ្នានៅព្រះវិហារសន្តីម៉ារីញញឹម នៃព្រះសហគមន៍កាតូលិកភូមិចំការទៀង ស្រុកត្រាំកក់ខេត្តតាកែវ នាល្ងាចថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៧ ដើម្បីប្រារព្ធពិធី បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ពេលចាប់ផ្តើមពិធី គ្រីស្តបរិស័ទទាំងអស់រួមជាមួយលោកអភិបាល និងបូជាចារ្យ បានជួបជុំគ្នាជុំវិញភ្នក់ភ្លើង ដើម្បីប្រារព្ធពិធីព្រះពរភ្លើង មានពន្លឺទានជ័យ ដែលជាពន្លឺ បញ្ជាក់នៃការរស់ឡើងវិញរបស់ព្រះយេស៊ូ។ បន្ទាប់មកមានពិធីដង្ហែទានទៅកាន់ទីសក្ការៈ។

នៅទីសក្ការៈគ្រីស្តបរិស័ទទាំងអស់បន្តប្រារព្ធពិធីលើកតម្កើងព្រះបន្ទូល ដែលរៀបរាប់ពីការរស់ឡើងវិញរបស់ព្រះគ្រីស្តជាអម្ចាស់។ ក្នុងរៀបរាប់ក៏មានការតាមរយៈពាក្យកាព្យ ក្នុងទម្រង់ចម្រៀងអាយ៉ៃខ្មែរ ដែលមានភ្លេងអាយ៉ៃកំដរ ក្រោយមកក៏មានអានអត្ថបទ ស្តីអំពីកំណើតពិភពលោក។

តាមជំនឿរបស់ព្រះសហគមន៍កាតូលិក បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ គឺជាបុណ្យធំជាងគេបង្អស់។ ដោយសារព្រះជាម្ចាស់ប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញទើបមានអ្នកជឿរហូតមកដល់សព្វថ្ងៃ។ បើព្រះយេស៊ូសោយទិវង្គតមិនរស់ឡើងវិញទេក៏គ្មានអ្នកជឿដូច្នេះដែរ។

ក្នុងធម្មទេសនាទៅកាន់គ្រីស្តបរិស័ទដែលចូលរួម លោកអភិបាលអូលីវីយេ ដែលជាអធិបតីក្នុងពិធីមានប្រសាសន៍ថា "ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ! អាលេលូ យ៉ា!អាលេលូយ៉ា!អាលេលូយ៉ា!"។ លោកលើកឡើងថា ព្រះអ ង្គមានព្រះជន្មគង់នៅ តើគង់នៅឯណា?

គឺនៅក្នុងចិត្តបងប្អូននៅទីនេះ បងប្អូនដែលទទួលជីវិតថ្មីថ្ងៃនេះ។ ដូចព្រះបន្ទូលថ្ងៃនេះ ទេវទូត ប្រាប់ក្រុមស្ត្រីថា កុំទៅរកព្រះអង្គនៅក្នុងផ្នូរ។ ព្រះអង្គឲ្យគេទៅជួបព្រះអង្គនៅស្រុកកាលីឡេ។

លោកថា សព្វថ្ងៃធ្វើដូចម្តេចដើម្បីជួបព្រះអង្គនៅកាលីឡេ?

"ខ្ញុំជឿថា កាលីឡេនៅទីនេះ នៅក្នុងបងប្អូន ក្នុងបងប្អូនថ្មីដែលទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ គឺទទួលឲ្យខ្យល់ដង្ហើមផ្ទាល់របស់ព្រះអង្គ។ ទទួលពន្លឺថ្មី ដែលមិនចេះរលត់"។

លោកអភិបាលបានរំឭកដល់គ្រីស្តបរិស័ទថា "សូមឲ្យយើងដែលទទួលជីវិតពីព្រះជាម្ចាស់ ទៅជាអ្នកដែលនាំជីវិតថ្មីដល់គេ។ យើងដែលទទួលពន្លឺ ត្រូវធ្វើជាពន្លឺដើម្បីអ្នកដទៃ។ យើងដែលទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ ត្រូវមានចិត្តស្រឡាញ់ដូចព្រះជាម្ចាស់"។

លោកបន្តថា សូមកុំឲ្យយើងនៅជាប់ជាមួយអ្នកដែលឆ្កាងព្រះយេស៊ូ។ សូមបើកភ្នែកមើលពិភពលោកនេះ មានសង្គ្រាមសម្លាប់មនុស្សយ៉ាងសន្ធឹកនៅស៊ីរី នៅអាហ្គានីស្ថាន អេហ្ស៊ីប។ "សូមឲ្យយើងបើកភ្នែកមើលប្រទេសយើង"។

មិនខ្វះទេអ្នកជិះជាន់អ្នកក្រីក្រ អំពើអយុត្តិធម៌មិនខ្វះទេ មនុស្សដែលបិទសិទ្ធិសេរីភាពអ្នកដទៃ មនុស្សពុករលួយមានបញ្ហាជាច្រើនទៀតដែលមនុស្សបន្តរឆ្កាងព្រះយេស៊ូតទៅទៀត។

លោកអភិបាលក៏បានលើកដែរថា ជួន-កាលក្នុងព្រះសហគមន៍យើងក៏ដូចគ្នាដែរ មានអ្នកនាំពាក្យមិនពិត និយាយបង្ខូចឈ្មោះ និយាយដើមគេ ជិះជាន់គេ មើលងាយគេ ច្រណែនគ្នា ឬឈប់និយាយរកគ្នា។ "បងប្អូនជាទីស្រឡាញ់កុំឲ្យយើងជាប់ជាមួយមនុស្សដែលឆ្កាងព្រះយេស៊ូ"។ ប៉ុន្តែយើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដ៏មានជីវិត ត្រូវចាំថាកាលីឡេ នៅទីនេះ ដើម្បីចេញទៅប្រកាសអំពីព្រះជាម្ចាស់មានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា។

លោកក៏បានជូនពរដល់គ្រីស្តបរិស័ទទាំងអស់ក្នុងឱកាសឆ្នាំថ្មី ឲ្យបានពោរពេញដោយពន្លឺ ឲ្យបងប្អូនបន្តស្រឡាញ់ បន្តបម្រើ បន្តប្រកាសនៅក្នុងកាលីឡេ នៅទីនេះ ដើម្បីឲ្យកម្លាំងនៃជីវិតថ្មី ឆ្ពោះមនុស្សទាំងអស់ ឲ្យមានកម្លាំងសារជាថ្មី និងមានសេចក្តីសង្ឃឹមសារជាថ្មី ។

បន្ទាប់ពីធម្មទេសនា សម្រាប់បុណ្យដ៏ឱឡារិកនេះលោកអភិបាលអូលីវីយេ ធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យបងប្អូន ជាមនុស្សពេញវ័យ និងកូនង៉ែត ចំនួន៥០នាក់ដើម្បីឲ្យពួកគេទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។

លោកអ៊ុយ ផើង ជាអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកថ្មី មកពីព្រះសហគមន៍កាតូលិកកំពង់អំពិល ក្នុងខេត្តតាកែវឲ្យដឹងថា លោកពិតជាមានអំណរខ្លាំងណាស់ ព្រោះថាតាំងពីជឿលើព្រះយេស៊ូ ជីវិតរបស់លោកបានផ្លាស់ប្រែច្រើន អំពីរបៀបរស់នៅមានសេចក្តីសង្ឃឹម និងផ្លូវចិត្តឲ្យបើកទូលាយច្រើនណាស់ស្រឡាញ់បងប្អូន។ លោកផើងក៏បានប្រកាសជំនឿថា "ព្រះយេស៊ូពិតជារស់ និងគង់ក្នុងរូបខ្ញុំពិតមែន"។ ទោះបីមានការរិះគន់ខ្លះអំពីការប្តូរជំនឿតែលោកនៅតែមានកម្លាំងជួបបងប្អូនដែលរិះគន់ទាំងនោះ។

ចំណែកលោកយាយ ម៉ម សឿន ដែលមានវ័យ ៧៧ឆ្នាំ មកពីព្រះសហគមន៍សន្តប៉ូល មានប្រសាសន៍ស្រដៀងនឹងលោកអ៊ុយ ផើងដែរ ថាថ្ងៃនេះពិតជាពេលត្រូវអរព្រះគុណព្រះជាម្ចាស់ខ្លាំងណាស់ ដែលព្រះអង្គបានត្រាស់ហៅឲ្យទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។ លោកយាយ បន្តថា នេះជាអំណរសប្បាយពិតប្រាកដ ដែលលោកយាយមិនដែលបានជួប។ ក្នុងគ្រួសាររបស់ព្រះគ្រីស្តនាំឲ្យលោកយាយ មានសង្ឃឹមថ្មី និងអំណរសប្បាយពិតប្រាកដ។

រីឯយុវតី ម៉ី គីមលីន មកពីព្រះវិហារសន្តីម៉ារីញញឹម ចំការទៀង បានឲ្យថា រីករាយណាស់ដែលទទួលជីវិតថ្មីរួមជាមួយព្រះគ្រីស្ត។ លីនប្រកាសថា នឹងខិតខំថែរក្សាជីវិតថ្មីនេះឲ្យជាប់ជាមួយពន្លឺរបស់ព្រះគ្រីស្ត ព្យាយាមប្រព្រឹត្តអំពើល្អ ចំពោះអ្នកដទៃ។

បុណ្យចម្លងឬបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញឆ្នាំ២០១៧ មានបងប្អូនទទួលជីវិតថ្មីតាមរយៈអគ្គសញ្ញាជ្រមុជទឹកក្នុងភូមិភាគភ្នំពេញចំនួនប្រមាណ ១២៨ នាក់ ដោយឡែកក្នុងខេត្តតាកែវមានចំនួន ៦៩នាក់។ ទូទាំងប្រទេសមានចំនួនប្រមាណជា៣០០នាក់ ដែលទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងព្រះសហគមន៍កាតូលិក។

*ដោយ លី សុវណ្ណា*

# កម្ពុជាកំពុងតែប្រញឹកដើម្បីឈានទៅរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់

នៅពេលនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណបក្សនយោបាយនានាដែលចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អណត្តិថ្មីកំពុងតែមមាញឹកនៅក្នុងការរៀបចំ ដើម្បីឲ្យដំណើរការរៀបចំការបោះឆ្នោតនៃថ្ងៃអាទិត្យ ទី០៤ មិថុនា ២០១៧ដំណើរការដោយរលូន។

គណៈកម្មកាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី០១ ខែឧសភា បានរៀបចំនូវវគ្គបណ្តុះបណ្តាលមួយ ដល់មន្ត្រីគណៈកម្មការរៀបចំការបោះឆ្នោតរាជធានីនិងខេត្ត, តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

លោកទេព នីថា អគ្គលេខាធិការនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានមានប្រសាសន៍ថា នេះជាការបណ្តុះបណ្តាលនៅដំណាក់កាលចុងក្រោយ មានទ្រង់ទ្រាយធំ ៤ថ្នាក់ដោយ ចាប់ផ្តើមពីពេលនេះទៅនៅថ្នាក់ជាតិ រួចបន្តទៅថ្នាក់ខេត្ត និងរាជធានី ថ្នាក់ប្រមូលផ្តុំក្រុងស្រុកខណ្ឌ និងថ្នាក់ប្រមូលផ្តុំឃុំ.សង្កាត់ ដែលនឹងបញ្ចប់នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត។ លោកបានបញ្ជាក់ថា "នេះជាដំណាក់កាលដ៏សំខាន់បំផុត ដែលកំណត់ជោគជ័យ ឬមិនជោគជ័យនៃការរៀបចំការបោះឆ្នោត។

លោកបានបន្តថា ការសម្រេចបានការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោតគ្រាន់តែជាលទ្ធផលសម្រេចបានតាមដំណាក់កាល ប៉ុន្តែការសម្រេចបានជោគជ័យបន្តទៀតក្នុងដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផលនៃការបោះឆ្នោត គឺជាជោគជ័យពេញលេញនៃការរៀបចំការបោះឆ្នោត ។

## កាលបរិច្ឆេទនៃការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១៧នេះ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី០៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៣រសៀល នៅការិយាល័យបោះឆ្នោត ដែលគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំសម្រាប់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដែលបានចុះឈ្មោះឡើងវិញសរុបចំនួន ៧.៨៦៥.០៣៣ នាក់។

## លក្ខខណ្ឌចាំបាច់ដើម្បីអាចចូលរួមការបោះឆ្នោត

ដើម្បីអាចចូលរួមដំណើរការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់បានគឺប្រជាពលរដ្ឋខ្មែរត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត ។

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបោះពុម្ពសន្លឹកឆ្នោតជាង៩,៤ លានសន្លឹក

លោកហង្ស ពុទ្ធា អ្នកនាំពាក្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានថ្លែងថា ចំនួនប្រជាពលរដ្ឋគ្រប់អាយុបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតមានតែជាង ៧,៨៦លាននាក់ទេ ប៉ុន្តែ គ.ជ.ប បានសម្រេចបោះពុម្ពសន្លឹកឆ្នោតសរុបចំនួនរហូតដល់ជាង ៩,៤២ សន្លឹក។ លោកបានថ្លែងថា ការបោះពុម្ពសន្លឹកឆ្នោតលើសនេះ គឺដើម្បីទុកបម្រុងសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដោយមួយការិយាល័យត្រូវមានសន្លឹកឆ្នោតបម្រុងទុកមួយក្បាល ឬយ៉ាងហោចណាស់ស្មើនឹង ៥០ សន្លឹក សម្រាប់ជំនួសចំពោះការខូចខាត ឬបាត់បង់ដោយប្រការណាមួយ។

លោកបានបន្តថា តាមការគ្រោងទុក ដំណើរការបោះពុម្ពសន្លឹកឆ្នោតទាំងនេះនឹងបញ្ចប់នៅថ្ងៃទី២៣ ឧសភា ហើយគ.ជ.ប នឹងដឹកជញ្ជូនទៅតាមការិយាល័យបោះឆ្នោតនីមួយៗ ដោយនៅក្នុងនោះគ.ជ.បក៏បានត្រៀមឧទ្ធម្ភាចក្រ ២គ្រឿងដើម្បីដោះស្រាយបញ្ហាជាយថាហេតុក្នុងការដឹកជញ្ជូនសន្លឹកឆ្នោតនេះផងដែរ។ លោកបានបញ្ជាក់ថា សន្លឹកឆ្នោតទាំងនេះ គឺមានការវេចខ្ចប់ និងបោះពុម្ព យ៉ាងប្រយ័ត្នប្រយែងដើម្បីធានាសុវត្ថិភាព ដោយមានយន្តការថ្មី ពោលគឺដើម្បីបង្ការការលួចបន្លំ ដោយមានទាំងលេខកូដសម្ងាត់ថែមទៀតផង។




## ប្រតិទិននៃដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១៧

ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អណត្តិទី៤ ឆ្នាំ២០១៧នេះ គឺបានឆ្លងកាត់ដំណាក់កាលនៃការរៀបចំជាបន្តបន្ទាប់ ប៉ុន្តែចាប់ពីពេលនេះដល់ការរាប់សន្លឹកឆ្នោតនៅឆ្លងកាត់ដំណាក់កាលមួយចំនួនទៀត ដែលគួរតែស្វែងយល់។

យោងទៅតាមប្រតិទិនដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឲ្យដឹងថា ពីថ្ងៃទី១៧ មេសា ដល់ថ្ងៃទី១៦ ឧសភា គឺកំពុងតែស្ថិតនៅក្នុងដំណើរការចែកប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោត បន្ទាប់មកគឺពីថ្ងៃទី២០ ឧសភា ដល់ថ្ងៃទី០២ មិថុនា គឺជាដំណាក់កាលនៃការឃោសនាបោះឆ្នោតដោយរយៈពេលនេះគឺមាន ១៤ ថ្ងៃ ។

ប្រភពដដែលបានបន្តថា បន្ទាប់មកនៅថ្ងៃទី០៣ មិថុនា ពោលគឺមុនការបោះឆ្នោតមួយថ្ងៃ គឺជាថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត បន្ទាប់មកនៅថ្ងៃទី០៤ មិថុនា គឺជាថ្ងៃនៃការបបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត។ ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតត្រូវបាន គ.ជ.បរំពឹងថា នឹងដំណើរការនៅថ្ងៃទី០៤ ទៅ០៥ ខែមិថុនា។

ប្រភពដដែលបានបន្តថា ការត្រួតពិនិត្យ ការបូកសរុប និងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ន គឺអាចពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែមិថុនា បន្ទាប់មកការប្តឹងជំទាស់លើលទ្ធផលបណ្តោះអាសន្ន គឺជារយៈពេល៣ថ្ងៃ ដោយចាប់ផ្តើមដល់ថ្ងៃទី១០ ខែមិថុនាជាថ្ងៃចុងក្រោយ ហើយការសម្រេចលើពាក្យបណ្តឹងជំទាសនៅកម្រិតមូលដ្ឋាន គឺមានរយៈពេល ៥ថ្ងៃ ដោយ ថ្ងៃទី១៥ ខែមិថុនាជាថ្ងៃចុងក្រោយ។ នៅក្នុងករណីមិនយល់ស្របនឹងការសម្រេចកម្រិតមូលដ្ឋាន ការសម្រេចលើពាក្យបណ្តឹងត៉វា ដោយ គ.ជ.ប គឺមានរយៈពេល ៤ថ្ងៃទៀត ដោយថ្ងៃទី២៤ ខែមិថុនា ជាថ្ងៃចុងក្រោយ។

ប្រភពដដែលបានបន្តថា ការប្រកាសផ្សាយនូវលទ្ធផលផ្លូវការនៃការបោះឆ្នោតនេះគឺនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែ មិថុនា ហើយនៅក្នុងករណីមានការបោះឆ្នោតសាជាថ្មី គឺ នឹងដំណើរការធ្វើឡើងនៅថ្ងៃទី២៤ ខែ កក្កដា ។

## គណៈបក្សនយោបាយដែលចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់

តាមការប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឲ្យដឹងថា គណបក្សនយោបាយដែលបានចុះឈ្មោះចូលរួមការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ នៅពេលខាងមុខនេះ គឺមាន១២គណបក្ស ដើម្បីបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សានេះចំនួន១១.៥៧២នាក់ សម្រាប់បម្រើការនៅឃុំ/សង្កាត់ទូទាំងប្រទេស ២៥ ខេត្ត និងរាជធានីចំនួន ១.៦៤៦ ឃុំ/សង្កាត់ ។

ប្រភពដដែលបានបន្តថា នៅក្នុងចំណោមគណបក្សទាំង១២ ដែលបានចុះឈ្មោះចូលរួមការបោះឆ្នោតនៅពេលខាងមុខនេះ គឺមានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិប៉ុណ្ណោះ ដែលមានបេក្ខជន ឬបេក្ខនារីនៅតាមឃុំ/សង្កាត់ទាំងអស់ ក្រៅពីនោះ គឺមានខ្លះអត់ខ្លះ។

ប្រភពដដែលបានបន្តថា គណបក្សដែលចូលរួមការបោះឆ្នោត ១០ គណបក្សទៀតរួមមាន គណបក្សហ៊្វុនស៊ីនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សខ្មែររួបរួមជាតិ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សសញ្ជាតិកម្ពុជា គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សយុវជនកម្ពុជា គណបក្សជនជាតិដើមប្រជាធិប-តេយ្យ គណបក្សអំណាចខ្មែរ និង គណបក្សសាធារណរដ្ឋប្រជាធិប-តេយ្យ។

*ដោយ អរិយបុត្រ*

# ដុំទឹកកកក៏ជាប្រភពនៃជីវភាពដ៏សមរម្យមួយ ដែលយើងមិនគួរនឹងមើលរំលង

ដើម្បីរស់នៅក្នុងជីវភាពមួយដ៏សមរម្យ មានមុខរបរជាច្រើនប្រភេទដែលប្រជាពលរដ្ឋកម្ពុជាកំពុងតែ ប្រកបមុខរបរតាំងពីការធ្វើការជាមន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន និងអង្គការសង្គមស៊ីវិល រហូតដល់អ្នកលក់ដូរនៅក្នុងមុខរបរផ្សេងៗ នៅក្នុងនោះ ក៏មានមុខរបរមួយចេញពីការលក់ទឹកកក ប្រជាពលរដ្ឋជាច្រើនដែលអាចរស់នៅក្នុងជីវភាពមួយសមរម្យបាន។

លោកសុន សារ៉ន អ្នកចែកចាយទឹកកកដែលមានវ័យ ៣៥ឆ្នាំ បានថ្លែងថា លោកនិងប្រពន្ធ គឺបានធ្វើការតាំងតែពីព្រះសូរិយាមិនទាន់មានពន្លឺរស្មី ដោយពួកគេបានក្រោកបញ្ឆាម៉ូតូរ៉ឺម៉ក ចេញពីផ្ទះជួលរបស់ពួកគាត់ ឆ្ពោះត្រង់ទៅកាន់រោងចក្រផលិតទឹកកកមួយកន្លែង ស្ថិតក្នុងសង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ ខណៈដែលអ្នកឯទៀតកំពុងតែលង់លក់ យ៉ាងស្កប់ស្កល់នោះ។

គាត់បានរៀបរាប់ថា "ខ្ញុំបានចាប់ផ្ដើមផើបតាំងពីម៉ោង ៣កន្លះព្រឹក ទៅយកទឹកកកពីរោងចក្រទៅដាក់ឲ្យអតិថិជនរៀងរាល់ថ្ងៃ រហូតដល់ម៉ោង១១ ថ្ងៃត្រង់ រួចទើបទៅផ្ទះជួល ដើម្បីហូបបាយហូបទឹករួចក៏សម្រាកបានប្រហែលជា ១ម៉ោងទៅ២ម៉ោង ក៏ចេញទៅចែកចាយទឹកកកបន្តទៀតរហូតដល់ម៉ោង ៧យប់ ទើបបានសម្រាក។

គាត់បានបន្តថា ការងារនេះហត់ ផងក្ដៅផង និងជួនកាលត្រជាក់ដែរពេលប៉ះទឹកកក។ លោកបានបន្តថា លោកបានធ្វើកិច្ចការនេះ ជាមួយនឹង ប្រពន្ធលោកផ្ទាល់ ហើយជារៀងរាល់ថ្ងៃពួកគាត់គឺត្រូវធ្វើដំណើរនៅក្នុងរង្វង់ប្រមាណជា ១២ គីឡូម៉ែត្រ។ របរដឹកទឹកកកនេះខុសពីរបរជាអ្នកលក់ទឹកកកតាមផ្ទះ ឬដាប់មាត់ផ្លូវ លោកសួន សារ៉ននិងភរិយាបានចាប់យកមុខរបរជាអ្នកចែកចាយទឹកកកចល័តនេះ ដោយសារតែលោកមានដើមទុនតិចតួច។ បុរស វ័យ៣៥ឆ្នាំ មកពីខេត្តកណ្ដាល រូបនេះបាននិយាយថា ការចាប់យកមុខរបរខាងលើគឺបន្តវេនពីបងប្រុស របស់លោក។

លោកបន្តថា លោកធ្លាប់មានរបរជាអ្នកដឹកទឹកកកលក់បែបនេះ រាប់ឆ្នាំមកហើយដែរប៉ុន្តែនៅពេលដំបូង គឺពិបាកមែនទែន។ លោកសួន សារ៉ន និងភរិយា បានតស៊ូជំនះលើការលំបាក អត់ឃ្លានហើយមានពេលខ្លះ ស្ទើរតែចង់បោះបង់ចោលមុខរបរនេះទៅហើយ ទម្រាំពួកគាត់អាចរកឃើញនូវស្ថេរភាព ក្នុងមុខរបរនេះនាពេលបច្ចុប្បន្ន។

អ្នកលក់ទឹកកករូបនេះបានបន្តថា ដោយសារតែមានដើមទុនតិចតួច ពេលចាប់ផ្ដើមដំបូង គឺគ្មានអតិថិជនច្រើននោះទេ ដោយសារលោកជាអ្នកចាប់ផ្ដើមថ្មី ហើយពុំសូវមានបទពិសោធច្រើន។ លោកបានបន្តថា នៅពេលនោះ គឺពិបាកមែនទែន ដោយលោកត្រូវដើររកអតិថិជនដើម្បីទប់ទល់នឹងឈ្នួលផ្ទះ។

លោកបានរៀបរាប់ទៀតថា មួយឆ្នាំដំបូង គឺពុំមានផលចំណេញសម្រាប់លោក និងប្រពន្ធនៅសល់ឡើយ ដោយសារលោកមានម៉ូយតិចពេក។ ប៉ុន្តែលោកចេះតែតស៊ូ រហូតដល់សព្វថ្ងៃ ទោះបីជា ចង់បោះបង់ចោលក៏ដោយ ប៉ុន្តែលោកគិតថាការងារដែលចាប់បានហើយធ្វើការបោះបង់ គឺគ្មានផ្លូវបន្តទៅមុខទៀតនោះទេ។

ចំណែកភរិយារបស់លោក ដែលកំពុងតែប្រកៀកស្មាគ្នាបន្តមុខរបរនេះ អ្នកស្រីហែម ស្រីនាង អាយុ២៩ឆ្នាំ មានដើមកំណើតនាទឹកដី ខេត្តកំពង់ឆ្នាំង បានធ្វើការលើកឡើងស្របគ្នាថា មុខរបរលក់ទឹកកកចល័តនេះចាប់ផ្ដើមជាមួយនឹងដើមទុនក៏មិនជាតិចប៉ុន្មានដែរ។

លោកស្រីបានបញ្ជាក់ថា "តាមខ្ញុំចាំ ពួកយើងចាប់ផ្ដើមជាមួយនឹងទុន ជាង២ពាន់ដុល្លា ដោយទុនមួយភាគធំ គឺបានមកពីការខ្ចីបុលគេ"។ លោកស្រីបានបង្ហើបឲ្យដឹងបន្ថែមទៀតថា ជាមួយមុខរបរនេះសព្វថ្ងៃពួកគាត់បានសងបំណុលគេរួចរាល់ ហើយថែមទាំងមានលទ្ធភាពទិញម៉ូតូថ្មី ដែលមិនសូវខូចដូចមុននឹងមិនសូវចំណាយកម្លាំងកាយ និងថវិកាសម្រាប់ជួសជុលថែមទៀត។

គូស្វាមីភរិយាមួយគូនេះយល់ថា ឧបសគ្គចម្បងនៃមុខរបរនេះគឺ ត្រូវពឹងផ្អែកលើភាពរឹងមាំនៃម៉ូតូ នៅថ្ងៃដែលម៉ូតូខូច ពួកគេត្រូវប្រឈមនឹងការស្ដីបន្ទោសពីសំណាក់អតិថិជន ដាច់បាយដាច់ទឹក និងខាតបង់ប្រាក់កាសជាដើម។

លោក សារ៉ន បានបន្តថា ការលក់ទឹកកក ផលលំបាកគឺ សំខាន់ពុំមានពេលទំនេរសម្រាកច្រើន ដែលត្រូវបន្តដាក់ឲ្យអតិថិជនបន្តរហូត ប៉ុន្តែការងារនេះមិនសូវជាយ៉ាប់យឺនប៉ុន្មានទេ គ្រាន់តែគ្មានម៉ោងសម្រាក។ លោកបានបន្តថា "និយាយរួមតាំងពីព្រលឹមរហូតដល់ព្រលប់ត្រូវធ្វើរហូត"។

លោកបានបន្តទៀតថា ការងារនេះគឺត្រូវចំណាយកម្លាំង ពេលវេលា និងការទាក់ទងម៉ូយ ហើយចំណុចមួយដែលអាចជាឧបសគ្គដែរនោះ គឺថាពេលខ្លះពិបាកដើរប្រមូលប្រាក់ពីអតិថិជន ពោលគឺត្រូវចេះ ប្រើចិត្តធ្ងន់ និងភាពអំណត់។

លោកបានរៀបរាប់ថា មុខរបរនេះពេលខ្លះក៏ហត់នឿយណាស់ដែរ ដោយត្រូវធ្វើការកម្លាំងមនុស្ស យ៉ាងតិច២នាក់។

លោកបានរៀបរាប់ថា បើសិនជាប្ដី ឬប្រពន្ធឈឺ គេត្រូវពឹងពាក់សាច់ញាតិ ឬជួលមនុស្សឲ្យជួយហើយ ទើបបានអាចទៅរួច។

តាមការរៀបរាប់របស់គូស្វាមីភរិយាមួយគូនេះ ទឹកកកមានអតិថិជនច្រើន នៅក្នុងរដូវក្ដៅ និងនៅថ្ងៃឈប់សម្រាក ដែលនាំឲ្យចំណូលពួកគាត់កើនឡើង ប៉ុន្តែទន្ទឹមនឹងនោះសុខភាពរបស់អ្នកលក់ ក៏ប្រឈមនឹងភាពទ្រុឌទ្រោមផងដែរ។

អ្នកស្រី ស្រីនាង បានបញ្ជាក់បន្ថែមថា អ្នកស្រីហត់នឿយ ប៉ុន្តែដើម្បីជីវិតចេះតែបន្តខំប្រឹងប្រែងទៅ។ បើទោះបីជាពួកគេលំបាក ហត់នឿយ នៅក្នុងរបរនេះក៏ដោយ ប៉ុន្តែពួកគេ បាននិយាយព្រមៗគ្នាថា ការលក់ទឹកកកជាមុខរបរសុចរិតមួយ។

មុខរបរនេះផ្ដល់ចំណូលដល់ពួកគាត់ជាមធ្យម ជាង១០ម៉ឺនរៀលក្នុងមួយថ្ងៃដែរ ហើយជាមួយនឹងប្រាក់ចំណូលនេះពួកគេសង្ឃឹមថា ក្នុងថ្ងៃអនាគតពួកគេ មានឱកាសនិងដើមទុនទៅប្រកបរបរផ្សេង នៅស្រុកកំណើត។

លោកសារ៉ន បានពន្យល់ថា មូលហេតុដែលលោកចង់ទៅរស់នៅស្រុកកំណើតមកពីមានភាពកក់ក្ដៅ ជួបជុំគ្រួសារ បងប្អូន ហើយពេលដែលចាកចេញពីស្រុក មានភាពនឹករលឹកផ្ទះ នឹកស្រុក។ ដែលពេលមានប្រាក់កាស គាត់អាចទៅធ្វើផ្ទះ ។

របរចែកចាយទឹកកកនេះ គឺជាមុខរបរមួយ ដែលគេដឹងថា បានបែកចេញមកពីរោងចក្រទឹកកក ដែលទីនោះ គឺមានបុគ្គលិក លើផ្នែកមួយចំនួន ដោយរួមទាំងគណនេយ្យ អ្នកគ្រប់គ្រង កម្មករ ថៅកែ... អ្នកចែកចាយទឹកកកមានអ្នកលក់ទឹកកក អ្នកប្រើប្រាស់ទឹកកក ជាច្រើន ប្រភេទ ជាច្រើនសេវាកម្មថែមទៀត។ សព្វថ្ងៃនេះ ទឹកកក គឺជាទំនិញដែលត្រូវបានគេប្រើប្រាស់សឹងតែសព្វយ៉ាងនៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសមញ្ញ ពោលគឺតាំងពីក្លាសេដាក់ភេសជ្ជៈ និងបង្អែមជាច្រើនប្រភេទ ...។

កញ្ញា សាញ់ ស្រីកា ជាអ្នកលក់ភេជ្ជៈតាមរទេះ ក៏បានឲ្យដឹង អំពីសារៈសំខាន់និងភាពចាំបាច់របស់ទឹកកកផងដែរថា ការលក់ការហ្វេក្ដី ទឹកក្រូច ទឹកបាកាស សូម្បីតែទឹកសុទ្ធ និងទឹកតែ គឺត្រូវតែមានទឹកកក ពីព្រោះអតិថិជនដែលមករកទទួលទានភេសជ្ជៈទាំងនេះ គឺកម្រមានអ្នកដែលមកទិញ ប្រាប់មិនឲ្យដាក់ ទឹកកកណាស់។ កញ្ញា បានបញ្ជាក់ថា "អ្នកដែលអត់ ត្រូវការទឹកកក គឺយូរៗ ជួបម្នាក់ទេ"។

*ដោយ ផានិត*



ថតដោយ ផានិត

## ប្រមុខរដ្ឋាភិបាលប្រកាសលុបចោលទោសជាប់ពន្ធនាគារនៃបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ

ចំថ្ងៃនៃទិវាសេរីភាពសារព័ត៌មានសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា រាជរដ្ឋាភិបាលបាន សម្រេចលុបចោលទោសជាប់ពន្ធនាគារនៃបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ និងបានធានាថាមិនមានប្រជាពលរដ្ឋណាម្នាក់ត្រូវបានជាប់ពន្ធនាគារដោយសារការបញ្ចេញមតិឡើយ។

នៅក្នុងសារលិខិតនាឱកាស "ទិវាសេរីភាពសារព័ត៌មានសកលលោក" នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧សម្តេចតេជោ ហ៊ុន សែន ក៏បានធ្វើការអំពាវនាវទៅដល់អ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ឲ្យបន្តយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយព័ត៌មានមិនពិត បំប៉ោងសភាពការណ៍ធ្វើឲ្យបាត់បង់តម្លៃព័ត៌មាន និងរុញច្រានស្ថានភាពនយោបាយប្រទេសឲ្យធ្លាក់ក្នុងស្ថានភាពវឹកវរ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំសូមអំពាវនាវដល់អ្នកសារព័ត៌មានជាតិអន្តរជាតិ ពិធីករ ពិធីការិនីស្ថានីយវិទ្យុ ទូរទស្សន៍ទាំងអស់ ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាសូមយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុង ហើយឆ្លុះបញ្ចាំងសភាពការណ៍ទាំងមូល ដោយពុំបានគិតអំពីក្បួនខ្នាតក្រឹត្យក្រមនៃការសរសេរសារព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានមិនពិត បំប៉ោងសភាពការណ៍ ធ្វើឲ្យបាត់បង់តម្លៃព័ត៌មាន និងរុញច្រានស្ថានការណ៍នយោបាយប្រទេសធ្លាក់ទៅក្នុងស្ថានភាពវឹកវរ អស្ថិរភាពនយោបាយ និងមានជម្លោះប្រដាប់អាវុធ"។

នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះគេដឹងថា មានកាសែតចំនួន ៥៣០ អង្គភាព ក្នុងនោះមានកាសែតផ្សាយជាភាសាបរទេសចំនួន ៤៣អង្គភាព ទស្សនាវដ្តីមានចំនួន ៣០៦ អង្គភាព ព្រឹត្តិបត្រព័ត៌មានមានចំនួន ៤២ អង្គភាព ការិយាល័យតំណាងទីភ្នាក់ងារសារព័ត៌មានបរទេស និងការិយាល័យតំណាងវិទ្យុទូរទស្សន៍បរទេសប្រចាំការអចិន្ត្រៃយ៍នៅកម្ពុជា មានចំនួន ២១ អង្គភាព ស្ថានីយវិទ្យុចំនួន២២១ ស្ថានីយទូរទស្សន៍ចំនួន ២២ និងទូរទស្សន៍ផ្សាយបន្តមានចំនួន ១១២ ស្ថានីយ ទូរទស្សន៍ផ្សាយតាមរណបតេជោ ឌីជី មាន០១ស្ថានីយ ទូរទស្សន៍ឌីជីថល (Pay-TV)មានចំនួន ០៤ ស្ថានីយ និងទូរទស្សន៍អនឡាញមានចំនួន ៥៨ អង្គភាព កំពុងដំណើរការធ្វើអាជីវកម្មនៅកម្ពុជា ៕

## សាលាដំបូងរាជធានីភ្នំពេញចេញបញ្ជាឲ្យសមត្ថកិច្ចនាំខ្លួនលោក ជុន ច័ន្ទបុត្រ

សាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែឧសភា បានចេញសេចក្តីថ្លែងការណ៍មួយ ដោយនៅក្នុងនោះ បានបញ្ជាក់អំពីការចេញដីកាឲ្យសមត្ថកិច្ចនាំខ្លួនឈ្មោះ ហួត ឃិនវុទ្ធី ហៅ ជុន ច័ន្ទបុត្រ ឲ្យមកបង្ហាញខ្លួន ដើម្បីធ្វើការស៊ើបអង្កេតករណីចោទប្រកាន់អំពីការបន្លំខ្លួនចូលពន្ធនាគារព្រៃស កាលពីពេលថ្មីៗនេះ។

ប្រភពដដែលបានបន្តថា ជុំវិញករណីនេះ កាលពីថ្ងៃទី២៨ ខែមេសា លោក ជុន ច័ន្ទបុត្រ បានជូន ដំណឹងមកតុលាការអំពីការចាកចេញរបស់ខ្លួនទៅប្រទេសថៃ ហើយនឹងត្រឡប់មកវិញនៅថ្ងៃទី០១ ខែឧសភា ដើម្បីចូលខ្លួនតាមកាលបរិច្ឆេទកោះហៅរបស់អយ្យការអមសាលាដំបូង ប៉ុន្តែនៅថ្ងៃទី០២ ខែដដែល បុគ្គលនេះមិនបានបង្ហាញខ្លួន ។

សូមបញ្ជាក់ថា លោក ជុន ច័ន្ទបុត្រ ដែលមានតួនាទីជានាយករងវិទ្យុអាស៊ីសេរីត្រូវបានគេចោទប្រកាន់ថា បានបន្លំខ្លួនចូលទៅក្នុងពន្ធនាគារព្រៃសជាមួយនឹងមន្ត្រីគណបក្សប្រឆាំង ដើម្បីទៅសាកសួរសុខទុក្ខបុគ្គលមួយចំនួនដែលកំពុងតែស្ថិតនៅមន្ទីរឃុំឃាំងនោះ កាលពីចុងខែមេសា ប៉ុន្តែនៅពេលនោះ លោកបានចាកចេញពីប្រទេសកម្ពុជាបាត់ទៅហើយ។

## រដ្ឋមន្ត្រីពាណិជ្ជកម្ម ជំរុញអាស៊ានយកចិត្តទុកដាក់លើការមកដល់នៃសេដ្ឋកិច្ចឌីជីថល

ក្រសួងពាណិជ្ជកម្មបានឲ្យដឹងថា កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជាសម្រាប់អាស៊ាន បានអញ្ជើញចូលរួមវេទិកាភាពជាអ្នកដឹកនាំអាស៊ានលើកទី១៤ ក្រោមប្រធានបទ "បង្កើនភាពជាដៃគូ វិបុលភាពជាមួយគ្នានៅក្នុងសេដ្ឋកិច្ចពិភពលោកថ្មីមួយ" ។

ប្រភពដដែលបានបន្តថា នៅក្នុងឱកាសនោះ លោក រដ្ឋមន្ត្រី បានលើកឡើងអំពីសារៈសំខាន់នៃការអភិវឌ្ឍសេវាកម្មតាមប្រព័ន្ធឌីជីថលសម្រាប់អាស៊ាន និងបានស្នើដល់អ្នកតាក់តែងគោលនយោបាយពិចារណាលើវិធានការមួយចំនួន ដើម្បីធ្វើឲ្យប្រសើរឡើងនូវទំនុកចិត្ត និងសន្តិសុខ នៅក្នុងសេដ្ឋកិច្ចឌីជីថលរបស់អាស៊ាន ដូចជា បន្តធ្វើបរិវត្តអ៊ីនធើណេត, ពន្លឿនការច្នៃប្រឌិតសេវាកម្មហិរញ្ញវត្ថុចល័ត និងពាណិជ្ជកម្មតាមអេឡិចត្រូនិក ព្រមទាំងតភ្ជាប់ទីក្រុងនៅក្នុងតំបន់។

លោកបានបញ្ជាក់ថា "នៅក្នុងឆ្នាំ២០២៥ បដិវត្តឌីជីថល អាចនឹងផ្លាស់ប្តូរជីវិតប្រចាំថ្ងៃនៅក្នុងតំបន់អាស៊ាន" ។

លោកបានលើកឡើងថា ការកើនឡើងនូវចំនួនប្រជាជនវ័យក្មេង ជាមួយទូរស័ព្ទវៃឆ្លាតយ៉ាងច្រើន បានផ្តល់ឱកាសសម្រាប់អាស៊ាន ក្នុងការបង្កើត និងអភិវឌ្ឍន៍សេវាកម្មឌីជីថលថ្មីៗ ជាពិសេសសេវាកម្មហិរញ្ញវត្ថុចល័ត និងពាណិជ្ជកម្មតាមអេឡិចត្រូនិក។

លោកបានបន្តថា សេដ្ឋកិច្ចឌីជីថលអាចមានអនុភាពខ្ពស់ ជាកម្លាំងចលករសម្រាប់ការធ្វើសមាហរណកម្ម ហើយនេះគឺជាហេតុផលសំខាន់ ដែលអាស៊ានគួរតែពិចារណាដាក់សេដ្ឋកិច្ចឌីជីថលជាគោលដៅអាទិភាព។

## កម្ពុជារៀបចំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីអំពីអាស៊ានដោយជោគជ័យ

ព្រះរាជាណាចក្រកម្ពុជាកាលពីពាក់កណ្តាលខែឧសភា បានរៀបចំមហាព្រឹត្តិការណ៍អន្តរជាតិមួយផ្នែកធុរកិច្ច គឺវេទិកាសេដ្ឋកិច្ចពិភពលោកស្តីអំពីអាស៊ានដោយជោគជ័យ ដោយមានការចូលរួម ពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំអាជីវកម្ម និងពាណិជ្ជករជាតិអន្តរជាតិ អ្នកសារព័ត៌មានសរុបប្រមាណជា ៧០០នាក់។

ព្រឹត្តិការណ៍រយៈពេល៣ ថ្ងៃ ដែលរៀបចំពីថ្ងៃទី១០ ដល់ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៧ គឺបានត្រូវបិទបញ្ចប់ ក្រោមវត្តមានរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង សមភាគីមកពីវៀតណាម និងឡាវ។

លោក ហ្វីលីប រ៉ូស្ល័រ ប្រធានផ្នែកសម្របសម្រួលនិងទំនាក់ទំនងរវាងរដ្ឋាភិបាលនិងតំបន់ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃវេទិកាសេដ្ឋកិច្ចពិភពលោក ដែលជាអ្នករៀបចំនូវព្រឹត្តិការណ៍នេះ បានថ្លែងថា វេទិកានេះបានបញ្ចប់ដោយជោគជ័យជាមួយនឹងលទ្ធផលជាផ្លែផ្កាជាច្រើន ហើយក៏បានសំដែងការដឹងគុណចំពោះគណកម្មការរៀបចំ និងក្រុមការងារជាពិសេសគឺប្រមុខរដ្ឋាភិបាលកម្ពុជាដែលបានគាំទ្រព្រឹត្តិការណ៍នេះរហូតដល់ទទួលបានជោគជ័យ។

ថ្លែងនៅក្នុងពិធីបិទវេទិកាសេដ្ឋកិច្ចពិភពលោកស្តីអំពីអាស៊ាននេះ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា វេទិកានេះបានបង្ហាញនូវឯកភាព និងសុខដុមនីយកម្មនៅក្នុងតំបន់ និងបានថ្លែងអំណរ គុណចំពោះមិត្តភ័ក្រ និងអ្នកចូលរួមមកពីផ្នែកផ្សេងៗ និងប្រទេសជាច្រើន ដែលបានមកចូលរួមនៅក្នុងមហាព្រឹត្តិការណ៍រយៈពេលបីថ្ងៃនេះ ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា "ខ្ញុំសង្ឃឹមថា វេទិកាពិភពលោកស្តីអំពីអាស៊ាននេះនឹងក្លាយជាវេទិកាដ៏មានសារៈសំខាន់ ដែលនឹងពង្រីកស្មារតីនៃសមាហរណកម្ម និងសាកលភាវូបនីយកម្ម"។

នៅក្នុងឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានប្រគល់នូវកណ្តឹងនិមិត្តរូបទៅនាយករដ្ឋមន្ត្រីវៀតណាម ដើម្បីធ្វើជាម្ចាស់ផ្ទះនៃវេទិកាសេដ្ឋកិច្ចពិភពលោកស្តីអំពីអាស៊ាននេះបន្តពីកម្ពុជានៅឆ្នាំក្រោយ ជាឆ្នាំទី ២៧ ។

គួររំលឹកថា មហាព្រឹត្តិការណ៍នេះ គឺបានទាក់ទាញអ្នកចូលរួម ប្រមាណជាជាង ៧០០នាក់មកពី៤០ប្រទេស។ នៅក្នុងចំណោមអ្នកចូលរួមទាំងអស់ គឺមានឥស្សរជនសំខាន់ៗ ដែលតំណាងឲ្យ រដ្ឋាភិបាលអាស៊ានទាំង១០ ចំនួន ៩០រូប ដោយនៅក្នុងនោះមានប្រមុខរដ្ឋាភិបាល ឡាវ និងវៀតណាម ព្រមទាំងប្រធានាធិបតីហ្វីលីពីន លោក រ៉ូឌ្រីហ្គោ ឌូតឺតេ ផងដែរ។ ក្រៅពីអ្នកនយោបាយ អ្នកជំនាញការ និងពាណិជ្ជករ ក៏មានអ្នកសារព័ត៌មានប្រមាណជា ២០០ ស្ថាប័ន រួមទាំងទូរទស្សន៍ធំៗកម្រិតអន្តរជាតិប្រមាណជា ១៤ ស្ថាប័នបានមក យកព័ត៌មាន និងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះផ្សាយចេញពីកម្ពុជា ។

នៅក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍នេះរយៈពេលបីថ្ងៃ ប្រមុខរដ្ឋាភិបាលកម្ពុជាបានជួបពិភាក្សាការងារ និងទ្វេភាគី ជាមួយនឹងប្រទេសក៏ដូចជាភ្ញៀវអន្តរជាតិពាណិជ្ជករធំៗជាច្រើនរូប ដែលកំពុងតែ វិនិយោគនៅកម្ពុជា និងកំពុងតែមានចំណាប់អារម្មណ៍មកបណ្តាក់ទុននៅកម្ពុជា។

# ពលរដ្ឋរអ៊ូសព្វយ៉ាងរឿងស្ថានភាពចរា

ប្រជាពលរដ្ឋដែលកំពុងតែរស់នៅស្រាប់ អ្នកដំណើរដែលឆ្លងកាត់ ឬមកលេងនៅរាជធានីភ្នំពេញ សរសើរអំពីការអភិវឌ្ឍន៍ ប៉ុន្តែម្នាក់ៗរអ៊ូរឿងស្ថានភាពចរាចរណ៍សព្វយ៉ាងរាប់ចាប់ពី គំនូសចរាចរណ៍ ភ្លើងបញ្ជាចរាចរណ៍ ការចតគ្មានសណ្តាប់ធ្នាប់ និងធ្វើរោងបុណ្យ ឬរោងការបិទផ្លូវរហូតដល់ការធ្វើឲ្យមានការកកស្ទះចរាចរណ៍។

កំពុងតែកាន់ចង្កូតម៉ូតូ នៅលើកំណាត់ផ្លូវមុនីវង្សតាមទិសពីភ្នំពេញឆ្ពោះទៅកាន់ផ្លូវជាតិលេខមួយ បុរសមាឌដំបង សម្បុរសជ្រះ ជិះម៉ូតូម៉ាកហុងតាភីស៊ីអ៊ិច (Honda PCX) ឈ្មោះហុង រង្សី បានឲ្យដឹងថា សម្រាប់អ្នករស់នៅទីក្រុងភ្នំពេញឥឡូវនេះ ដាច់ខាតត្រូវតែមានទាំងម៉ូតូ និងរថយន្ត បើមិនដូច្នោះទេ ធ្វើការមិនទាន់ផង។

លោកបានថ្លែងថា ស្ថានភាពចរាចរណ៍នៅក្នុងរាជធានីភ្នំពេញឥឡូវអាថ្វាធរហាក់ដូចជាដោះស្រាយមិនចេញទេ គឺមានតែភាពឆ្លាតវៃនៃការធ្វើដំណើរទេទើបអាចធ្វើដំណើរបានលឿន ទៅធ្វើការ ឬរកស៊ីទាន់ពេល ។

លោកបានបញ្ជាក់ថា "ឥឡូវនេះឡានជិះបានតែពេលណាចង់រំភើយ មិនសូវប្រញាប់ទេ បើចង់រហ័សត្រូវជិះម៉ូតូ ប៉ុន្តែពេលខ្លះសូម្បីតែម៉ូតូ ក៏ត្រូវជាប់ស្ទេញទៅណាមិនរួចដែរកុំថា តែឡាន"។

លោកបាននិយាយបែបនេះនៅក្នុងខណៈពេលដែលមហាវិថីមុនីវង្សពីកំណាត់ចាប់ពីមុខ សាលាវិទ្យាល័យបឹងត្របែកដល់ស្ពានអាកាសក្បាលថ្នល់កំពុងតែស្ទះចរាចរណ៍យ៉ាងណែនក្តន់ កាលពី វេង្វង់ម៉ោង ៦:១៥នាទីល្ងាច ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧។




*រូបភាពឯកសារ ស្ពានព្រះមុនីវង្សថ្មី*

លោក រង្សី បានថ្លែងបន្តថា ផ្លូវណាក៏ដូចផ្លូវណាដែរឥឡូវនេះ គឺវាណែនចឹងហ្មង។ ម៉ូតូអាចបើក គេចចុះគេចឡើងរកផ្លូវចេញ តាមចញ្ចើមខ្លះ តាមច្រកតូចៗខ្លះ គ្រាន់បានធូរអារម្មណ៍ តែបើឡានវិញគឺចប់ហ្មង តែបើស្ទះជួនកាល១ ម៉ោងអីកន្លែងខ្លះវិលកង់មិនបាន១០ ជុំផង។

លោក ពេជ្រ សុវណ្ណ អ្នកដំណើរមួយរូប ដែលស្ថិតនៅក្នុងភាពកកស្ទះមួយរូបដែរ ប៉ុន្តែនៅលើ កំណាត់ផ្លូវ ២៧១ ពីចំណុចមុខអាគារការិយាល័យស្ថាប័នមីក្រូហិរញ្ញវត្ថុប្រាសាក់ ដល់រង្វង់ ច្រកចូលវត្តសន្សំ-កុសលបានថ្លែងថា និយាយមិនចេញទេរឿងចរាចរណ៍នៅស្រុកយើងឥឡូវនេះ។

លោកបានរអ៊ូបញ្ជាក់ថា "នរណាដែលឮជិះម៉ូតូត្រឹមតែពីកន្លែងធ្វើការនៅពោធិ-ចិនតុង មកផ្ទះនៅ ផ្សារប៉េសេ ២ ម៉ោងទៅណាមិនរួច"។

លោកបានបន្តថា រាល់ដងពេលធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះនេះត្រឹមតែ ១ ម៉ោងអីទេ ហើយ បើយូរបំផុតត្រឹម ១ ម៉ោងកន្លះ ប៉ុន្តែថ្ងៃនេះ ជាង ២ម៉ោង អត់ទាន់ដល់។ ផ្លូវវាស្ទះពេក ហើយរោង ការរោងបុណ្យវាច្រើន។ លោកបានថ្លែងបន្តទៀតថា រាល់ដងលោកច្រើនតែគេចជិះតាមផ្លូវតូចៗ នៅក្នុងភូមិ ប៉ុន្តែពេលនេះជិះទៅណាក៏ជួបតែ រោងបុណ្យ និងរោងការ

## ពលរដ្ឋសុំឲ្យអាជ្ញាធរយកចិត្តទុកដាក់បន្តិចរឿងអប់រំនិងជួសជុលភ្លើងបញ្ជាចរាចរណ៍

ពលរដ្ឋដែលកំពុងតែធ្វើដំណើរនៅរាជធានីភ្នំពេញបានសំណូមពរដល់អាជ្ញាធរយកចិត្តទុកដាក់បន្តិច រឿងអប់រំអំពីការប្រើប្រាស់ផ្លូវចរចរណ៍ថ្មី និងសុំឲ្យយកចិត្តទុកដាក់ជួសជុលភ្លើងចរាចរណ៍ដែលខូច ឬមានកំហុសបច្ចេកទេសផង ។

នៅក្នុងខណៈពេលដែលភ្លើងចរាចរណ៍ថ្មីនៅរាជធានីភ្នំពេញប្រមាណជាជាង ១០០កន្លែង កំពុងតែតម្លើង និងដាក់ឲ្យដំណើរការនោះ។ ពេជ្រ សុវណ្ណ ជាប្រជាពលរដ្ឋមួយរូប បានអរគុណដល់អាជ្ញាធរដែលតម្លើងភ្លើងស្តុបថ្មី ដែលមានទំហំធំ និង ស្ថានភាពល្អជាងភ្លើងចាស់ ប៉ុន្តែលោកវង្វេង ដែរពេល ធ្វើដំណើរហើយវគ្គនឹងភ្លើងស្តុបនេះនៅកន្លែងខ្លះ ។

លោកបានបន្តថា ភ្លើងតែមួយនេះនៅកន្លែងខ្លះ ពេលភ្លើងខៀវ គឺអាចធ្វើដំណើរទៅទាំងអស់ ទាំងបទឆ្វេង បទស្តាំ និងទៅមុខដល់ក្រហមបានឈប់ទាំងអស់គ្នាឲ្យម្ខាងទៀតទៅ តែកន្លែងខ្លះពេលខៀវហើយអាទៅមុខយើងអាចបើកទៅមុខបានតែបត់ឆ្វេងមិនបានទេ អ្នកត្រូវបត់ឆ្វេងរង់ចាំសិនដល់ភ្លើងខៀវអ្នកទៅមុខលោតភ្លើងក្រហម ហើយភ្លើងបត់ឆ្វេងចេញខៀវបានបត់បាន។ ប៉ុន្តែកន្លែងខ្លះ គឺពេលភ្លើងខៀវលោត ទៅមុខទៅបានតែក្រោយមកបន្តិច បានលោត សញ្ញាខៀវឲ្យអ្នកបទឆ្វេង ហើយក៏ក្រហមវិញ ប៉ុន្តែអ្នកទៅមុខនៅតែខៀវអាចទៅដដែល។ លោកបានបញ្ជាក់ថា "ដល់វាច្រើនស្តង់ដារពេកតចឹងទៅ ពេលខ្លះចង់វង្វេង ពេលឈប់ស្តុបម្តងៗ មិនដឹងត្រូវទៅ ឬឈប់ តែបើបានមានសេចក្តីជូនដំណឹង ឬពន្យល់ចំណុចនេះប្រហែលជាវាជួយអ្នកបើកបរបានច្រើនដែរ "។

លោកហេង ស័ក្តិ ជាអ្នកដំណើរមួយរូបដែលធ្លាប់មានបញ្ហានឹងភ្លើងចរាចរណ៍ថ្មីនេះ ក៏បានសំណូមពរឲ្យមានការពន្យល់ ឬអប់រំអំពីការប្រើប្រាស់ភ្លើងចរាចរណ៍ថ្មីនេះដែរ។ ហើយម្យ៉ាងទៀត លោកក៏បានសំណូមពរឲ្យអាជ្ញាធរមេត្តាដោះអាភ្លើងស្តុបចាស់ផង ពីព្រោះអាស្តុបថ្មីច្រើន តម្លើងក្រោយ អាស្តុបចាស់នាំឲ្យពិបាកមើល។

# ចរណ៍នៅរាជធានីភ្នំពេញបច្ចុប្បន្ន




ក៏ត្រឡប់មកឡើងលើ ផ្លូវ២៧១នេះជាប់ស្ទេញតែម្តង ។

លោកមិនបានឃើញអំពីមូលហេតុដែលបណ្តាលឲ្យស្ទះនាអំឡុងពេលដែលលោកបានជាប់គាំង នោះទេ ប៉ុន្តែ លោកបានប៉ាន់ស្មានថា មូលហេតុដែលស្ទះនោះ គឺគ្មានអ្វីក្រៅពីរថយន្តដឹកដែក ឬដឹកឥវ៉ាន់វាបត់ចូលដេប៉ូ ឬឆ្លងកាត់នោះទេ។

លោកបានបញ្ជាក់ថា "ថ្ងៃមុនមិនស្ទះយ៉ាងម៉េច បើអាឡានដឹកទំនិញឲ្យប៉ុនយក្ស ដឹកទំនិញឲ្យពេញវាមកបត់លើប្រឡោះទ្រូងផ្លូវ ដែលគេទុកឲ្យម៉ូតូ ឡានតូចឆ្លងផ្លូវនេះ"។ លោកបានបញ្ជាក់ទៀតថា "បត់យ៉ាងម៉េច ម៉ោង៦:៣០ល្ងាច មនុស្សឲ្យពេញ ហើយឡាននោះវាប៉ុនយក្ស មិនស្ទះគេ មិនស្ទះឯង"។

ជុំវិញការកកស្ទះចរាចរណ៍នៅលើដងវិថី និងមហាវិថីនានានៅក្នុងរាជធានីភ្នំពេញនេះ ក្រៅពីបញ្ហា កំណើនយានយន្ត ការសាងសង់រោងការ ឬរោងបុណ្យនៅលើទ្រូងផ្លូវ ការអនុញ្ញាតឲ្យយានយន្តធំៗធ្វើដំណើរឆ្លងកាត់រាជធានី នៅពេលដែលស្ថានភាពចរាចរណ៍ ណែនណាន់តាន់តាប់ បញ្ហានៃការ បើកបរគ្មានសណ្តាប់ធ្នាប់ បញ្ហាចំណតនៅលើទ្រូងផ្លូវ ភ្លើងបញ្ជាចរាចរណ៍ និងប៉ូលីសចរាចរណ៍ តែម្តងក៏សុទ្ធតែជាចំណុច ដែលអ្នកដំណើរបានលើកឡើងថា ជាមូលហេតុដែលបង្កឲ្យមានការកកស្ទះនៅក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះ។

លោក លីវ ចេងស៊ីន ជាប្រជាពលរដ្ឋនៅរាជធានីភ្នំពេញមួយរូប បានមានប្រសាសន៍ថា ជុំវិញការកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញនេះ ថ្ងៃណាមួយច្បាស់ជាមានរឿងធំជម្លោះធំដុំដោយសារតែវាមិនខានឡើយ។ លោកបានបន្តថា ឥឡូវនេះយើងធ្លាប់ឮមាត់ឮករ និងការទាក់សំដីគ្នា ជាញឹកញាប់នៅលើទ្រូងផ្លូវនោះអត់និយាយអំពីរឿងរអ៊ូក្នុងឡាន ឬរអ៊ូម្នាក់ឯងនោះទេ ។

លោកបានបញ្ជាក់ថា " ទាំងខ្ញុំទាំងគេពិតជាធុញខ្លាំងណាស់ ពេលស្ទះម្តងៗ"។ លោកបានបន្តទៀតថា ពេលខ្លះ ការកកស្ទះចរាចរណ៍នេះ វាកើតឡើងដោយមិនសមនឹងស្ទះសោះ តែម្តង។

លោកបានបន្តទៀតថា សព្វថ្ងៃនេះនៅតាមផ្លូវមួយចំនួន ដូចជាមហាវិថីមុនីវង្សជាដើម ឲ្យតែកន្លែងភ្លើងស្តុប គឺមានម្ខាងរីកម្ខាងរួម ចំណែកផ្លូវវាត្រូវជំតូច ប៉ុន្តែមានសណ្ឋាគារ និងភោជនីយដ្ឋានខ្លះដែលនៅកាច់ជ្រុងនោះ គឺយកទ្រូងផ្លូវកន្លែងដែលរួមនោះចតរថយន្តមិនត្រឹមតែនៅលើចិញ្ចើមទេ គឺថែមទាំងនៅលើទ្រូងផ្លូវទៀត ដូច្នេះផ្លូវដែលត្រូវធ្វើដំណើរ គឺមានតែមួយប្រក ដែលល្មមត្រឹម តែ រថយន្តមួយគ្រឿងប៉ុណ្ណោះអាចធ្វើ ដំណើរបាន សូម្បីតែម៉ូតូ បើកស្របទិសគ្នា ធ្វើដំណើរនៅក្នុងពេលតែមួយក៏មិនបានផង នោះហើយគឺជាបញ្ហា។

លោកបានបញ្ជាក់ទៀតថា "ខណៈពេលអាផ្លូវវាកំពុងតែតូចស្រាប់ ហើយថែមទាំងមានឡានចតនៅលើផ្លូវទៀតនោះ វារិតតែគួរឲ្យខឹងទៅទៀតពេលដែលភ្លើងខៀវត្រូវទៅហើយ មានអាឡានខ្លះអត់ទៅទេ នៅស៊ីញ៉ូ ចាំបត់ចូលហាង ឬអូតែលនេះថែមទៀត ដោយមិនខ្វល់ថាអ្នកណាស្ទះអីស្ទះទៅ។ ឥចឹងៗអីមិនឲ្យគេខឹងយ៉ាងម៉េច"។

លោក ហ៊ិន បុញ្ញាឫទ្ធិ ជាអាជីវករមួយរូបដែលរស់នៅខេត្តកំពត បានមានប្រសាសន៍នៅ ហាងគុយទាវ មួយកន្លែងនៅក្បែរគុកទួលស្លែងថា ភ្នំពេញឥឡូវពិតជាធំហើយប្លែករីកចម្រើនមែន ផ្លូវក៏ខ្វាត់ខ្វែងច្រើន ប៉ុន្តែរឿងចរាចរណ៍ គឺដូចជាគ្មានសណ្តាប់ធ្នាប់សោះតែម្តង។

លោកបានបញ្ជាក់ថា "ផ្លូវនៅភ្នំពេញឥឡូវនេះ តែបើកឡានមិនស្រួល ស្ទះមុខស្ទះក្រោយអី ខ្ញុំវង្វេងតែម្តង។ ថ្ងៃមុនពីផ្ទះកូននៅផ្សារដេប៉ូរ ទៅផ្ទះប្អូននៅម៉្តុំវង្វង់មូលខាំកូរង្វេងចង់ពីរម៉ោង ទាល់តែបើកមកដល់ ស្ពានជ្រោយចង្វាបានភ្ញាក់ខ្លួនស្វាងពីរង្វេង " ។

លោកបានបន្តថា បញ្ហាយានយន្តនៅទីក្រុងយើងប៉ុណ្ណឹង បើសិនជាបើកបរគោរពគ្នា គោរពភ្លើងសញ្ញា ហើយកន្លែងដែលកកស្ទះមានប៉ូលីសជួយអន្តរាគមន៍អី គឺប្រហែលជាមិនអីនោះទេ ប៉ុន្តែពេលខ្លះ មិនគោរពភ្លើងចរាចរណ៍តែម្តងអាភ្លើងក្រហមក៏បើករុលគីរុលទៅ ដល់គេខាងខៀវគេរុលដែរជល់គ្នា ទៅណារួច។ ពេលខ្លះដូចជានៅរង្វង់មូល កន្លែងមានផ្លូវប្រសព្វច្រើនជាដើម បើសិនមានប៉ូលីស ឬអាជ្ញាធរនៅជួយសម្រួលចរាចរណ៍មិនអីទេ ប៉ុន្តែពេលខ្លះ ប៉ូលីសដូចជាមិនរវល់តែម្តង ។

ជុំវិញបញ្ហានេះ មន្ត្រីប៉ូលីសចរាចរណ៍មួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណបានមានប្រសាសន៍ថា មិនមែនមន្ត្រីប៉ូលីសចរាចរណ៍គ្មានឆន្ទៈដោះស្រាយរឿងកកស្ទះនេះទេ ប៉ុន្តែពេលខ្លះ បើស្ទះខ្លាំង គឺមន្ត្រីម្នាក់ ទៅ២នាក់ អីគឺដោះមិនចេញតែម្តង ។

លោកបានបញ្ជាក់ថា "ខ្ញុំពេលខ្លះអស់ចិត្តតែម្តង សុខចិត្តអង្គុយមើលស្រួលមិនហត់។ ដោះម៉េចម៉ាផ្លូវមានប៉ូលីសតែម្នាក់ទៅពីរម្នាក់នោះ បើម៉ូតូ និងឡានរាប់រយគ្រឿងពេញទាំងផ្លូវ ទាំងស្តាំទាំងឆ្វេង ទាំងពីរទាំងបីទិស ហើយពេលខ្លះមិនស្តាប់ប៉ូលីសតែម្តង។ បើប្រាប់ឡានឲ្យឈប់ អាម៉ូតូរុល ហើយឃាត់អាស្តាំ អាឆ្វេងមិនស្តាប់ " ។

*ដោយ អរិយបុត្រ*

## កំណើនយានយន្តកើនឡើងគួរឲ្យកត់សំគាល់

ដោយសារតែកំណើនសេដ្ឋកិច្ច និងកម្រិតប្រាក់ចំណូលប្រជាពលរដ្ឋនៅក្នុងប្រទេសកំណើននៃការប្រើប្រាស់យានយន្ត គឺមានការកើនឡើងគួរឲ្យកត់សំគាល់។

យោងតាមតួរលេខស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនប្រចាំត្រីមាសទី១ឆ្នាំ២០១៧ បានឲ្យដឹងថា ការចុះបញ្ជីយានយន្តនៅក្នុងរយៈពេលនេះមានចំនួនសរុប ១០៣.២៦៤ គ្រឿង នៅក្នុងនោះរថយន្ត ១៣.០៩៩ គ្រឿង និង ម៉ូតូ ៩០.១៦៥ គ្រឿង ។

ប្រភពដដែលបានបន្តថា ចាប់តាំងពីឆ្នាំ២០១៥មកទល់ចុងឆ្នាំ២០១៦ កំណើនយានយន្តនៅទូទាំងប្រទេសបានបន្តកើនឡើងខ្ពស់ដល់ទៅចំនួន៥៥៣% ក្នុងនោះម៉ូតូកើនឡើងចំនួន ៣៧២% និងរថយន្តគ្រប់ប្រភេទកើនឡើង ១៨១% សរុបមានម៉ូតូចំនួន ២.៧១៤.១៩៣គ្រឿង និងមានរថយន្តគ្រប់ប្រភេទចំនួន ៤៨៦.១២៧គ្រឿង៕

# ការជួបជុំលើកទី៩ ប្រារព្ធខួបការស្រង់រូបសំណាកព្រះនាងម៉ារី


ថតដោយ សម្បត្តិ

គ្រីស្តបរិស័ទជាតិនិងអន្តរជាតិជួបជុំគ្នាដើម្បីប្រារព្ធពិធីបុណ្យអរព្រះគុណព្រះជាម្ចាស់ចំពោះខួប៩ឆ្នាំ នៃការស្រង់រូបសំណាកព្រះនាងម៉ារីចេញពីទន្លេមេគង្គ ដែលមានលោកអភិបាល អន់តូនីសាមី ស៊ូសៃរាជ្យ ជាប្រធានកម្មវិធីអភិបូជា រួមជាមួយលោកបូជាចារ្យបួនអង្គទៀត នៅឯព្រះវិហារព្រះមាតានៃសន្តិភាព ស្ថិតនៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល។

លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលនៃព្រះសហគមន៍កាតូលិកនៃភូមិភាគកំពង់ចាមមានប្រសាសន៍ក្នុងធម្មទេសនាថា ព្រះនាងម៉ារីដែលជាមាតាព្រះយេស៊ូ ជាគំរូសម្រាប់យើងគ្រប់គ្នាក្នុងការបម្រើអ្នកដទៃដោយនឹកដល់សេចក្តីត្រូវការរបស់គេជាមុន។ លោកអភិបាលបន្តថា គ្រប់ពេលដែលមនុស្សមានរបួសចិត្ត គឺគេមិនអាចមើលឃើញនូវសេចក្តីល្អផ្សេងៗរបស់អ្នកដទៃបានទេ ហើយក៏មិនអាចឲ្យពន្លឺរបស់ព្រះជាម្ចាស់ចូលជ្រៅក្នុងដួងចិត្តបានដែរ ពីព្រោះចិត្តពោពេញដោយកំហឹង។

លោកអភិបាលបន្ថែមថា "ក្នុងជីវិតរស់នៅរបស់យើង យើងអរគុណគេតិច យើងសង្ស័យគេច្រើន យើងញញឹមតិច តែយើងខឹងច្រើន ចិត្តរបស់យើងរករឿងគេច្រើន មិនចង់អរគុណគេទេ ជាហេតុនាំឲ្យយើង(ក្លាយ)ជាអ្នករបួសចិត្ត។ អ្នករបួសចិត្តគិតតែ(អំពី)ខ្លួនឯង ហើយសង្ស័យគេរហូត"។ លោកអភិបាលបានផ្តល់ដំបូន្មានដល់គ្រីស្តបរិស័ទដែលចូលរួមជាង១០០០នាក់ថា នៅពេលយើងជួបបញ្ហានេះ យើងត្រូវតែថ្វាយបង្គំព្រះជាម្ចាស់ដោយស្ងាត់ស្ងៀម តមអាហារ អង្វរព្រះជាម្ចាស់ឲ្យយើងចេះលើកលែងទោសដល់អ្នកដទៃ គឺឲ្យយើងរួចពីរបួសចិត្តនេះ។ នៅថ្ងៃនេះ ទោះបីយើងទទួលពិធីជ្រមុជទឹកតាំងពីយូរហើយ យើងក៏ទទួលស្គាល់ថា ចិត្តរបស់យើងនៅតែរឹងរូស និងកាចសាហាវ។ យើងសូត្រផ្តាំលុតជង្គង់អធិដ្ឋាន តែជម្រៅចិត្តយើងមិនលើកលែងទោសដល់អ្នកដទៃទើបយើងពិបាកស្រឡាញ់គេ។ ប៉ុន្តែយើងត្រូវហ៊ានស្រឡាញ់គេ នាំឲ្យយើងអាចនៅក្បែរព្រះយេស៊ូ ដូចព្រះនាងម៉ារី គឺយើងព្រមទទួលព្រះយេស៊ូក្នុងជីវិតរបស់យើងហើយ។


ថតដោយ សម្បត្តិ

នៅក្នុងខួបលើកទី៩ ក្នុងថ្ងៃទី២២ មេសានេះ ជាការស្រង់រូបសំណាកព្រះនាងម៉ារីដែលបានស្រង់ចេញកាលពីខែមេសា ឆ្នាំ២០០៨ ដោយអ្នកនេសាទសាសនិកអ៊ីស្លាមម្នាក់។ ក្នុងរយៈកាលប៉ុន្មានឆ្នាំមកនេះ ព្រះសហគមន៍អរិយក្សត្របានទទួលស្វាគមន៍គ្រីស្តបរិស័ទមកពីទីជិតឆ្ងាយទាំងក្នុង និងក្រៅប្រទេស ដែលមកអធិដ្ឋានទូលអង្វរព្រះជាម្ចាស់តាមរយៈព្រះនាងម៉ារី ដែលប្រសិទ្ធិនាមថា ព្រះមាតានៃទន្លេមេគង្គ។

ដាង ធិហាយ ហ្វុក សេស៊ីលីយ៉ា មកពីប្រទេសវៀតណាម បាននិយាយថា ការដែលបានឮអំពីព្រះនាងម៉ារីនៅប្រទេសកម្ពុជា គាត់និងឪពុកក៏សម្រេចចិត្តមកឲ្យស្គាល់និងអធិដ្ឋានទៅកាន់ព្រះនាង។ សេស៊ីលីយ៉ា បន្តថា "ខ្ញុំនិងឪពុកមកទីនេះ គឺដើម្បីអធិដ្ឋានដល់ព្រះនាងម៉ារីសុំសេចក្តីសុខសាន្តសម្រាប់ក្រុមគ្រួសារយើង"។ នាងបន្តថា ថ្វីត្បិតតែប្រទេសកម្ពុជាមានគ្រីស្តបរិស័ទតិចតួចជាងវៀត-ណាមក្តី តែព្រះជាម្ចាស់បានបង្ហាញការអស្ចារ្យដល់បងប្អូននៅទីនេះ។ នាងពិតជាមានសេចក្តីសោមនស្សណាស់ដែលបានមកដល់ទីនេះ។

តាមប្រសាសន៍របស់លោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍អរិយក្សត្រ លោក អាដ្រីយ៉ាន បេនីតេស្ត ហ្គូស្តាវ៉ូ មានប្រសាសន៍ថា ព្រះវិហារនេះ ត្រូវបានដាក់ជាកន្លែងសម្រាប់ធ្វើបូជនីយចរសម្រាប់ព្រះសហគមន៍ទូទាំងប្រទេស ដូច្នេះគម្រោងការរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញនឹងជ្រើសរើសទីតាំងមួយថ្មីដែលទូលាយជាងនេះ ដើម្បីទទួលគ្រីស្តបរិស័ទជាច្រើនដែលចង់មកអធិដ្ឋានតាមរយៈព្រះនាងម៉ារី ទៅកាន់ព្រះជាម្ចាស់។ លោកបូជាចារ្យមានប្រសាសន៍ទៀតថា "ទោះបីកន្លែងតូចមែន តែក៏មានភាពកក់ក្តៅ។ បងប្អូនជាច្រើនបានស្គាល់កន្លែងយើងហើយ គាត់មកជារៀងរាល់ឆ្នាំ ម្តងហើយម្តងទៀតដើម្បីអធិដ្ឋានទៅព្រះនាងម៉ារី។ ច្បាស់ហើយកន្លែងធំគឺល្អ។ ខ្ញុំគិតថា ព្រះនាងម៉ារីបានរៀបចំ ហើយព្រះនាងនឹងរៀបចំដែរកន្លែងសំណាកធម៌(ថ្មី)"។

*ដោយ កញ្ញា*

# មរណសាក្សីបានផ្ដល់ក្ដីសង្ឃឹមដល់គ្រីស្ដបរិស័ទនៃព្រះសហគមន៍កាតូលិកកម្ពុជា

ព្រះសហគមន៍កាតូលិកកម្ពុជា បានរៀបចំពិធីបុណ្យនឹករឭកដល់មរណសាក្សីទាំងអស់ ដែលបានពលីជីវិតដោយជំនឿនាសម័យខ្មែរក្រហម។ ពិធីបានប្រារព្ធនៅទឹកដីមរណសាក្សី ភូមិតាំងគោក ស្រុកបារាយណ៍ ខេត្តកំពង់ធំកាលពីថ្ងៃទី១ ឧសភា ២០១៧នេះ ក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញអូលីវីយេ ដ្មឺតអឺស្ដែរ និងលោកអន់តូនី ស៊ូសែរាជ្យ អភិបាលភូមិភាគកំពង់ចាម ដោយមានគ្រីស្ដបរិស័ទចូលរួមប្រមាណ ៣០០០នាក់ មកពីព្រះសហគមន៍នានាទាំងបីភូមិភាគ។

ជាកិច្ចចាប់ផ្ដើមកម្មវិធី លោកអភិបាល និងលោកបូជាចារ្យទាំងអស់បានហែចូលមកឈរជុំវិញព្រះឈើឆ្កាងនៃមរណសាក្សី ដោយមានក្រុមឆៃយ៉ាំនាំមុខ ដើម្បីអធិដ្ឋាននឹករឭកដល់មរណសាក្សីទាំងអស់មុននឹងចាប់ផ្ដើមអភិបូជា។

ក្នុងធម្មទេសនា លោកអភិបាលអន់តូនី បានមានប្រសាសន៍លើកទឹកចិត្តគ្រីស្ដបរិស័ទទាំងអស់ដោយលើកយកគំរូ និងប្រវត្តិរបស់លោក ហ្វ្រង់ស្វ័រ ទ្រៀង ជាអភិបាលមួយរូបដែលបានជាប់ពន្ធនាគារនៅប្រទេសវៀតណាម ដើម្បីបង្ហាញឲ្យអ្នកចូលរួមទាំងនោះយល់នូវស្ថានភាពនៃជីវិត។ លោកថា "មនុស្សយើងមានគ្រាសប្បាយ និងទុក្ខលំបាក។ ច្រើនដងយើងធ្លាក់ទឹកចិត្តពេលដែលឃើញទុក្ខលំបាកក្នុងជីវិត"។ ទន្ទឹមនឹងនេះ លោកអភិបាលអន់តូនី បានលើកយកពាក្យរបស់លោក ហ្វ្រង់ស្វ័រ ទ្រៀង ថា "ទុក្ខលំបាកអ្វីក៏ដោយ មិនឲ្យយើងធ្លាក់ទឹកចិត្តនិងអស់សង្ឃឹមទេ តែផ្ទុយទៅវិញគឺត្រូវទុកចិត្តលើព្រះជាម្ចាស់គ្រប់ពេលវេលា"។

ក្រោយមកទៀតលោកអន់តូនី បានលើកយកប្រវត្តិនៃដីមរណសាក្សី និងអត្ថន័យនៃរូបឈើឆ្កាងដែលបានបង្ហាញអំពីទុក្ខវេទនារបស់គ្រីស្ដបរិស័ទខ្មែរក្នុងសម័យខ្មែរក្រហម ដោយពួកគាត់ប្រកាន់ខ្ជាប់នូវជំនឿ ទោះបីស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត ដែលជាជាគំរូនៃជំនឿគ្រីស្ដបរិស័ទបច្ចុប្បន្ន។

លោក ដាង ប៊ុនហាប់ មកទីនេះព្រោះចង់ដឹងថានៅទីនេះមានអ្វីប្រែប្រួលខុសពីប៉ុន្មានឆ្នាំមុន និងដើម្បីសម្រាកពីការគិតអំពីការងារ ជាពិសេសតាមរយៈមរណសាក្សី ដូចលោកអន់តូនីបានទេសនា ដែលបានផ្ដល់កម្លាំងចិត្តដល់លោក ព្រោះលោកថា មនុស្សម្នាក់ៗតែងតែមានទុក្ខលំបាករៀងៗខ្លួន។ យុវជនហាប់ បន្ថែមថា "ការងារខ្ញុំសព្វថ្ងៃមានសម្ពាធ និងទុក្ខលំបាកជាច្រើនដែរ ក៏ប៉ុន្តែបន្ទាប់ពីបានស្ដាប់នូវសេចក្ដីពន្យល់ពីលោកអភិបាលតូនីអំពីអត្ថន័យឈើឆ្កាង និងទុក្ខលំបាកនៅជំនាន់ខ្មែរក្រហមរួចមក ធ្វើឲ្យខ្ញុំទទួលបានចម្លើយផ្ទាល់ខ្លួនថា ទោះបីជាលំបាកយ៉ាងណាក៏ដោយ ក៏ត្រូវចាំថាមានព្រះជាម្ចាស់គង់ជាមួយជានិច្ច ដែលធ្វើឲ្យខ្ញុំមានក្ដីសង្ឃឹម នឹងបន្តការងាររបស់ខ្ញុំតទៅមុខទៀត"។



ថតដោយ សម្បត្តិ

រីឯកញ្ញា ម៉ាការីតា ជា សុវណ្ណចាន់បុប្ផា បានឲ្យដឹងថា មរណសាក្សីពិតជាសំខាន់នៅក្នុងជីវិតគ្រីស្ដបរិស័ទ ជាពិសេសជីវិតខាងជំនឿរបស់យើង ព្រោះពួកគាត់គឺជាអ្នកដែលជំរុញឲ្យយើងមានជំនឿតាមរបៀបការប្រកាសដំណឹងល្អនៅក្នុងការរស់នៅរបស់ពួកគាត់ ដែលធ្វើឲ្យខ្ញុំតែងតែពន្យល់ប្រាប់អ្នកស្វែងយល់ជំនឿអំពីពួកគាត់ផងដែរ។

ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ ប្រទេសកម្ពុជាធ្លាក់ក្នុងរបបមួយដែលគេហៅថា គុកឥតជញ្ជាំង ប្រជាជនត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង រដ្ឋអំណាចបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរ ហើយទទួលរបបអាហារតិចតួច គឺហូបតែបបរប៉ុណ្ណោះ។ មានមនុស្សជាច្រើនបានត្រូវគេសម្លាប់ ព្រោះតែការចោទប្រកាន់ដោយការកាត់សេចក្ដីគ្មានហេតុផល។ ក្នុងនោះមានបងប្អូនគ្រីស្ដបរិស័ទកាតូលិក លោកអភិបាលព្រះសហគមន៍កាតូលិក លោកបូជាចារ្យ និងដូនជី ព្រមទាំងបព្វជិតកាតូលិកជាច្រើនរូប។ គ្រប់គ្រាដែលរងទុក្ខលំបាកគ្រីស្ដបរិស័ទនៅកាន់ភ្ជាប់នូវជំនឿ។ លោកអភិបាល លោកបូជាចារ្យ ដែលបានសច្ចានៅលីវអស់មួយជីវិត ដែលជាច្រើនលើកច្រើនសារត្រូវគេបង្ខំឲ្យរៀបការ តែលោកមិនព្រម។ លោកបូជាចារ្យត្រូវគេសម្លាប់ព្រោះតែងាជាប្រជាជនថ្មីជាដើម។

ឆ្នាំ២០០០ សន្តអសនៈបាននុញ្ញាតឲ្យព្រះសហគមន៍កាតូលិកនៅកម្ពុជាយកថ្ងៃទី៧ ខែឧសភា ជាថ្ងៃរំឭកដល់គ្រីស្ដបរិស័ទនៅកម្ពុជាដែលបានបូជាជីវិតនៅក្នុងសម័យកាលដ៏សែនវេទនានោះ។

សព្វថ្ងៃនេះព្រះសហគមន៍កាតូលិកនៅកម្ពុជាកំពុងប្រមែប្រមូល ព័ត៌មាននានាដែលទាក់ទងនឹងជីវិត លោកអភិបាល លោកបូជាចារ្យនិងគ្រហស្ថ ដើម្បីរៀបចំចងក្រង ដាក់បញ្ចូលក្នុងបញ្ជីមរណសាក្សីជាផ្លូវការ។

*ដោយដាលីស*



ថតដោយ សម្បត្តិ

# ព្រះសហាគមន៍កាតូលិកតាកែវ ប្រើទម្រង់ល្ខោនបាសាក់ ដើម្បីរៀបរាប់អំពី ទុក្ខលំបាក់របស់ព្រះយេស៊ូ



ថតដោយ លី សុវណ្ណា

នៅពេលដែលប្រជាជនខ្មែរត្រៀមខ្លួនចូលរួមអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរបស់ខ្លួន។ ប៉ុន្តែគ្រីស្តបរិស័ទកាតូលិកទូទាំងប្រទេសកម្ពុជា បានប្រារព្ធបុណ្យរំឭកអំពីទុក្ខលំបាករបស់ព្រះយេស៊ូ។ ជាថ្ងៃដែលព្រះអង្គត្រូវគេកាត់ទោស ត្រូវគេធ្វើទារុណ និងត្រូវឆ្កាងសម្លាប់ចោល យ៉ាងអាម៉ាស់បំផុត និងអយុត្តិធម៌បំផុត។

ដោយឡែកគ្រីស្តបរិស័ទព្រះសហគមន៍កាតូលិកតំបន់តាកែវ និងកំពតបានមកជួបជុំគ្នា នៅព្រះសហគមន៍កាតូលិកភូមិចំការទៀងខេត្តតាកែវ ដើម្បីលើកតម្កើង និងនឹករឭកដល់ព្រះយេស៊ូដែលសោយទិវង្គត ក្រោមអធិបតីភាពលោកអូលីវយេជាអភិបាល។ ពិធីបានចាប់ផ្តើមដោយព្រះបន្ទូលរៀបរាប់អំពីការកាត់ក្តី ដោយឆ្កាងព្រះអង្គ តាមទម្រង់ល្ខោនបាសាក់ ដែលសម្តែងដោយ យុវជនយុវនារី នៅលើឆាកដ៏ល្អប្រណិត។

តាមជំនឿរបស់គ្រីស្តបរិស័ទ ព្រះយេស៊ូសុគតព្រោះតែអំពើអាក្រក់របស់មនុស្ស ព្រះអង្គយាងមកដើម្បីឲ្យមនុស្សកែប្រែចិត្តគំនិត។

យុវគ្រីស្តបរិស័ទ ណាន បាននិយាយថា កាលបានទស្សនា ការសម្តែងល្ខោនបាសាក់រឿងទុក្ខលំបាករបស់ព្រះយេស៊ូ នាងពិតជាមានក្តីរន្ធត់ និងបានរិះគិតអំពីទង្វើរបស់ខ្លួន ពេលខ្លះបានប្រព្រឹត្តមិនគប្បី មិនបានប្រព្រឹត្តតាមព្រះបន្ទូលបានល្អ មិនយកចិត្តទុកដាក់អ្នកដទៃ មិនរវីរវល់នឹងអ្នកក្រីក្រ ព្រមទាំងខឹងច្រើនជាដើម។ ទាំងនោះសុទ្ធតែជាអំពីបាប ដែលបានឆ្កាងព្រះយេស៊ូ បដិសេធព្រះយេស៊ូ។

ចំណែកកញ្ញា យ៉ាន់ ស្រីសា ជាគ្រីស្តបរិស័ទ និងជាអ្នកអង្គុយទស្សនានិយាយថា នាងពិតជាពិបាកសម្តែងអារម្មណ៍ណាស់នៅពេលនាងបានទស្សនា នាងគ្រាន់តែថាខឹងណាស់នៅពេលដែលសាវ័ករបស់ព្រះយេស៊ូម្នាក់ គឺយូដាអ៊ីស្ការីយ៉ូត ដែលក្បត់ព្រះយេស៊ូ។ ខឹងលោកសិលាដែលប្រកែកថាមិនស្គាល់ព្រះយេស៊ូចំនួនបីដង គឺធ្វើឲ្យនាងមានអារម្មណ៍ថាខឹងខ្លាំងណាស់។ ជាងនេះទៅទៀតនាងរៀបរាប់ថា ត្រង់ឈុតគេវាយធ្វើបាប និងឆ្កាងព្រះយេស៊ូ នាងពិតជាក្តុកក្តួលក្នុងចិត្តឥតឧបមា នាងត្រូវស្រក់ទឹកភ្នែកទាំងមិនដឹងខ្លួនទៅតាមសាច់រឿង និងឈុតឆាកនីមួយៗ។

ក្រោយការទស្សនា បានធ្វើឲ្យនាងយល់ និងដូចជាបានមើលឃើញពីការរងទុក្ខលំបាករបស់ព្រះយេស៊ូផ្ទាល់ភ្នែកតែម្តង។ លោកសិលាប្រកែកថាមិនស្គាល់ព្រះយេស៊ូបីដងនោះ នាំឲ្យនាងគិតថា ពិតមែនមនុស្សយើងគឺអាត្មានិយមណាស់ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន សូម្បីតែគ្រូខ្លួនឯងក៏ប្រកែកថាមិនស្គាល់នៅក្នុងកាលៈទេសៈដ៏ពិបាកមួយ ។

ឧត្តម ជាតួអង្គព្រះយេស៊ូ បានចាប់អារម្មណ៍ថា នៅពេលសម្តែងគាត់សុខចិត្តឲ្យតួអង្គទាហាន យករំពាត់វាយលើខ្លួន គឺកុំឲ្យគ្រាន់តែវាយត្រឹមជាលក្ខណៈសម្តែងអី គឺគាត់សុខចិត្តឈឺសាច់មែនទែន ព្រោះគាត់ខ្លាចនៅពេលដែលតួទាហានវាយមិនត្រូវផង តែបែរជាត្រូវធ្វើពត់ជាឈើ គាត់ខ្លាចថាគេមិនអាចចូលតួបាន ១០០ភាគរយ។

ជាតួអង្គព្រះយេស៊ូបើប្រៀបធៀបជីវិតគាត់ផ្ទាល់ទៅនឹងព្រះយេស៊ូ ឧត្តមបានថ្លែងថា ពិតជាឈឺចាប់ និងហួសចិត្តជាខ្លាំងពេលដែលត្រូវសិស្សរបស់ខ្លួនឯងក្បត់បែបនេះ ហើយក៏ហួសចិត្តពីការចោទប្រកាន់ពីសំណាក់ប្រជាជនទាំងឡាយផងដែរ។

ឧត្តម ជាសិស្សវិទ្យាល័យសន្ត ប្រ៊្វង់ស្វ័រម្នាក់ ដែលជាពុទ្ធបរិស័ទ។ ក្រោយពីគាត់បានសម្តែងជាតួព្រះយេស៊ូ ឧត្តមមានការភ្ញាក់ផ្អើលជាខ្លាំងអំពីជីវិតរបស់ព្រះយេស៊ូ គាត់គោរពកោតសរសើរព្រះយេស៊ូជាខ្លាំង ដែលទ្រង់សុខចិត្តរងទុក្ខលំបាកគ្រប់បែបយ៉ាង និងសុខចិត្តសុគតនៅលើឈើឆ្កាង ទាំងដែលគ្មានទោសសោះបែបនេះ។

ចំណែកយុវតី ឈុយ វិច្ឆិកា ជាសិស្សថ្នាក់ទី១១ ផ្នែកចំណេះដឹងទូទៅនៃវិទ្យាល័យសន្ត ប្រ៊្វង់ស្វ័រ សម្តែងជាតួអង្គនាងម៉ារីជាមាតាព្រះយេស៊ូ។ វិច្ឆិការៀបរាប់ថា នាងរំភើបផង ភ័យផងដោយនាងខ្លាចក្រែងថានាងមិនអាចសម្តែងបានល្អ។ នាងបន្តទៀតថា មិនងាយស្រួលប៉ុន្មានទេ នៅពេលដែលនាងត្រូវដើរតួជាម្តាយ។ វិច្ឆិកាត្រូវសួរអារម្មណ៍របស់ម្តាយនាងពេលនៅផ្ទះថា តើម្តាយនាងមានអារម្មណ៍បែបណាប្រសិនជាគាត់បានឃើញកូនគាត់ត្រូវគេវាយធ្វើបាប និងត្រូវឆ្កាងសម្លាប់នោះ វិច្ឆិកាត្រូវរៀនពីម្តាយនាងពីអារម្មណ៍បែបនេះ និងក្រោយមកគេក៏យកអ្វីដែលម្តាយនាងបានប្រាប់ និងបង្ហាញពីអារម្មណ៍ ក៏បានធ្វើឲ្យនាងអាចបញ្ចូលតួជាម្តាយបានយ៉ាងល្អ។

វិច្ឆិកាបន្តទៀតថា នៅពេលដែលឃើញទាហានវាយធ្វើបាបព្រះយេស៊ូ ធ្វើឲ្យនាងស្រែកយំមែនទែនតែម្តង គឺមិនមែនគ្រាន់តែជាការសម្តែងនោះឡើយ។ នាងថាអារម្មណ៍ជាម្តាយនៅពេលនោះគឺថា ប្រសិនជាអាចនាងសុខចិត្ត ឲ្យទាហានវាយធ្វើបាបនិងឆ្កាងនាងជំនួសព្រះយេស៊ូវិញ។ នាងបន្តថា "ព្រះយេស៊ូពិតជាអស្ចារ្យណាស់។ នាងពិតជាក្តុកក្តួលនឹងអ្វីដែលព្រះយេស៊ូបានលះបង់សម្រាប់មនុស្សលោកយ៉ាងមហិមារបែបនេះ ហើយនាងចង់ស្វែងយល់ពីជីវិតព្រះយេស៊ូឲ្យកាន់តែស៊ីជម្រៅជាងនេះទៀតផងដែរ។

ពិធីបុណ្យបានបានបន្តដោយដង្ហែឈើឆ្កាងចូលក្នុងព្រះវិហារដោយស្ងៀមស្ងាត់ ហើយគ្រីស្តបរិស័ទ គោរពព្រះឈើឆ្កាងដោយដួងចិត្តក្តុកក្តួល និងមមៃដល់ព្រះយេស៊ូ។

*ដោយ ដាលីស*

# លោកបែរណាដូរ ម៉ម បុប្ផានី (១៩២២-១៩៧៥)

## Mr. Bernardo MAM BOPHANI

## អ្នកលេងភ្លេងនិងអ្នកលេងអ័រហ្គេនក្នុងព្រះវិហារ



លោកកើតនៅភ្នំពេញ ភូមិព្រះមាតា ឆ្នាំ១៩២២ ឪពុកឈ្មោះម៉ម បូ ឌីម៉ុងតេរ៉ូ ម្តាយឈ្មោះ បា សូផាវង្ស។ ជាកូនច្បងបង្អស់ មានប្អូនគឺ ម៉ម ប៊ុតណារី, ម៉ម ប៊ុតណារ៉ាយ, ម៉ម បូឡាគ្រី។ លោក រៀននៅក្នុងសាលាព្រះមាតា ក្រោយមកនៅក្នុងសាលាមីស្ស រហូតដល់បាក់ឌុប។

លោកមានចរិតស្លូតបូត ជំនឿរបស់គាត់រឹងមាំ កាន់សាសនាត្រឹមត្រូវ។ លោកមានបច្ចេកទេស ខាងព្យាណូ (Piano) មានឈ្មោះល្បី។ លោកជាអ្នកលេងភ្លេងនៅក្នុងអាសនវិហារ (Cathedral) ប៉ុន្តែលេងជាប្រចាំនៅក្នុងព្រះវិហារ ភូមិព្រះមាតា។ លោកបានជួយហាត់ចម្រៀងក្រុមចម្រៀងនៅព្រះវិហារព្រះមាតានោះ ដោយចិត្តគោរពដើម្បីថ្វាយបង្គំព្រះជាម្ចាស់។ លោករំលឹកប្អូនដែលលេងភ្លេងដូចគ្នាថា "លេងភ្លេងថ្វាយព្រះអង្គទៅព្រះអង្គប្រទានពរឲ្យ"។

លោកមានគ្រួសារនៅភ្នំពេញ មានកូនប្រុសមួយកូនស្រីពីរ។ ជីវិតគ្រួសារដំបូង មានការពិបាក ព្រោះលោកស្រឡាញ់ស្រីដែលឪពុកម្តាយមិនពេញចិត្ត។ ក្រោយមកបានធ្វើពិធីអាពាហ៍ពិពាហ៍ត្រឹមត្រូវ។ លោកធ្វើការនៅក្រសួងហិរញ្ញវត្ថុ ផ្នែកលេខាធិការ។

ក្រោយមកលោកបានទៅរៀន នៅប្រទេសបារាំង ២ ឆ្នាំ ផ្នែកតន្ត្រី និងទៅរៀនភ្លេងនៅអាល្លឺម៉ង់ ថ្នាក់បណ្ឌិត។ ពេលនោះ ជាជំនាន់លន់ នល់ ហើយក្រោយមក នៅពេលពួកខ្មែរក្រហមកាន់កាប់ភ្នំពេញ ក៏ផ្តល់ដំណឹងឲ្យប្រជាជនខ្មែរដែលនៅស្រុកក្រៅឲ្យត្រឡប់មកវិញ ប្រហែលក្រោយមកគ្រប់គ្រងប្រទេសបីខែ ដោយប្រាប់ថា ស្រុកមានសេចក្តីសុខសាន្តហើយ។

ពេលលោកមកដល់ ពួកទាហានធ្វើល្បិចស្វាគមន៍ ហើយក្រោយមក ក៏ចូលមន្ទីរឃុំឃាំងទួលស្លែង ពេលនោះប្រហែល ចុងឆ្នាំ ១៩៧៥ ហើយស្លាប់ជាមួយប្រជាជនដែលគ្មានកំហុសនៅគុកនោះ។



សន្ត យ៉ូហាន នៃឈើឆ្កាង

លោក យ៉ូហានកើតនៅប្រទេស អេស្ប៉ាញ នៅក្នុងឆ្នាំ១៥៤២ ពីក្រុមគ្រួសារក្រីក្រ។ កាល គាត់អាយុ២៥ឆ្នាំ គាត់ទទួលអគ្គសញ្ញាជាបូជាចារ្យក្នុងក្រុមគ្រួសារបព្វជិតការមែល។ ក្រោយមក គាត់ជួបនាងថេរេសា នៃទីក្រុងអាវីឡា ជាដូនជីតាមែលម្នាក់ ដែលសុំឲ្យគាត់ជួយកែទម្រង់ក្រុមគ្រួសារបព្វជិតការមែលខាងបុរស។ ប៉ុន្តែ បព្វជិតខ្លះប្រឆាំងនឹងការកែទម្រង់នេះ ចាប់លោក យ៉ូហាន ដាក់ក្នុងគុកធ្វើបាបគាត់។ នៅក្នុងមន្ទីរឃុំឃាំង យ៉ូហាន បាននិពន្ធសៀវភៅបរិយាយអំពីជីវិតរួមរស់ជាមួយព្រះយេស៊ូ ក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ប្រាំបួនខែក្រោយមក លោកយ៉ូហាន រត់គៀសខ្លួនចេញពីគុក។ គាត់មានប្រសាសន៍ថា ពេលគាត់នៅក្នុងគុក គាត់មានចិត្តពោរពេញដោយអំណរសប្បាយ ព្រោះគាត់បានរងទុក្ខលំបាកចំពោះព្រះយេស៊ូ។

សន្ត យ៉ូហាន នៃឈើឆ្កាង សរសេរថា

-ត្រូវតែរស់នៅក្នុងលោកនេះ ដូចជាមានតែអ្នក និងព្រះជាម្ចាស់ប៉ុណ្ណោះ។ ធ្វើដូច្នោះ ចិត្តរបស់អ្នកនឹងមិនជាប់នឹងកិលេសតណ្ហាទេ។

-កាលយើងផុតជីវិត ព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសយើង ដោយឈ្វេងយល់តែសេចក្តីស្រឡាញ់ប៉ុណ្ណោះ។ ដូច្នេះត្រូវតែលះបង់អ្វីៗទាំងអស់ ដើម្បីស្រឡាញ់ព្រះជាម្ចាស់តែមួយព្រះអង្គគត់ ។

- ទុក្ខលំបាកទាំងប៉ុន្មាន ជាឱកាសដ៏ប្រសើរមួយ ដើម្បីរួមទុក្ខនឹងព្រះយេស៊ូដែលស្រឡាញ់ យើងនៅលើឈើឆ្កាង។ ដូច្នេះទោះបីយើងរងទុក្ខលំបាកក៏ដោយ ក៏យើងអាចមានចិត្តពោរពេញដោយអំណរសប្បាយដែរ។

**មាត្រា ៣៣៖**

អ្នកជិះ អ្នកដឹក ឬអ្នកបរសត្វ ត្រូវអនុវត្តដូចខាងក្រោម៖

១- មិនត្រូវបង្កឲ្យមានឧបសគ្គ ឬគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវទៀត ដោយត្រូវដាក់ចំនួនមនុស្សដឹកឲ្យសមស្របនឹងចំនួនសត្វដែលអាចបញ្ជាសត្វឲ្យទៅ ឬឈប់បានគ្រប់គ្រាន់ និងទានពេលវេលា។

២- នៅពេលយប់ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់ ត្រូវប្រើភ្លើងពណ៌សនៅខាងមុខ និភ្លើងពណ៌ក្រហមនៅខាងក្រោយ។

៣- នៅពេលឈប់នៅលើទ្រូងផ្លូវ មិនត្រូវបង្កឲ្យរំខានដល់យានជំនិះផ្សេងៗទៀតដែលកំពុងធ្វើចរាចរណ៍។

៤- នៅក្នុងទីប្រជុំជន អ្នកជិះ អ្នកដឹក ឬអ្នកបរសត្វនៅលើទ្រូងផ្លូវត្រូវឈប់នៅតាមទិសដែលខ្លួនកំពុងធ្វើចរាចរណ៍ ដោយអនុវត្តដូចខាងក្រោម៖

- ចំពោះទ្រូងផ្លូវដែលមានទិសចរណ៍ពីរ ត្រូវឈប់ខាងស្តាំតាមទិសចរាចរណ៍របស់ខ្លួន

- ចំពោះទ្រូងផ្លូវឯកទិស ត្រូវឈប់ខាងស្តាំ ឬខាងឆ្វេងតាមទិសចរាចរណ៍លើកលែងតែមានផ្លាកសញ្ញាហាមឃាត់។

៥- ហាមលែងសត្វឲ្យដើររហេតរហូតលើផ្លូវ។

# ច្បាប់ចរាចរណ៍ ផ្លូវគោកថ្មី

**ជំពូកទី៦**

**ករណីមានគ្រោះថ្នាក់ចរាចរណ៍**

**មាត្រាទី ៣៤៖**

គ្រប់ករណីគ្រោះថ្នាក់ចរាចរណ៍ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ផ្លូវគោក។ នៅរាល់ករណីគ្រោះថ្នាក់ចរាចរណ៍ នគរបាលចរាចរណ៍ផ្លូវគោកត្រូវខិតខំឲ្យអស់សមត្ថភាពដើម្បី៖

១- រក្សាសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងកើតហេតុ។

២- ចាត់វិធានការសង្គ្រោះជនរងគ្រោះជាបន្ទាន់។

៣- រក្សាសន្តិសុខឲ្យដល់គ្រប់ភាគីពាក់ព័ន្ធ ទប់ស្កាត់ជម្លោះដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍។

៤- ចាត់វិធានការជំនាញ ប្រមូលភស្តុតាង និងព័ត៌មានដើម្បីធ្វើកំណត់ហេតុស្តីពីគ្រោះថ្នាក់ចរាចរណ៍។

# សម្ដេចប៉ាប មរណសាក្សី គឺជាឈាមស្រស់នៃព្រះសហគមន៍

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ថ្មីៗនេះបានថ្លែងថា មរណសាក្សី គឺមានតួនាទីសំខាន់ខ្លាំងណាស់ សម្រាប់ព្រះសហគមន៍កាតូលិកនៅទូទាំងពិភពលោក ពោលគឺថា ពួកគេគឺជាឈាមតេកឈាមស្រស់ៗ នៃព្រះសហគមន៍កាតូលិកតែម្ដង ។

យោងទៅតាមសេចក្ដីរាយការណ៍របស់វិទ្យុវ៉ាទីកង់ បានឲ្យដឹងថា ការថ្លែងកត់សំគាល់អំពី សារៈសំខាន់នៃមរណសាក្សីនេះ គឺធ្វើឡើង ដោយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃសៅរ៍សប្ដាហ៍មុន នៅពេលអញ្ជើញចូលរួមជាអធិបតីនៃ ទិវាអប់រំជំនឿពិភពលោកនៅព្រះវិហារសន្តបាថូឡូមេ ។

នាឱកាសនោះ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍សង្កត់ធ្ងន់ នៅពេលធ្វើធម្មទេសនាថា មរណសាក្សីគឺជា មូលដ្ឋានគ្រឹះដែលតំណាងឲ្យសេចក្ដីក្លាហាន ដែលបានបូជាជីវិតដើម្បីការពារភាពស្ងប់ និងសេចក្ដីមេត្តាករុណា និងសេចក្ដីស្រលាញ់ និងដំណឹងល្អរបស់ព្រះសហគមន៍។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា តាមប្រវត្តិសាស្ត្រ យើងតែងតែឮអំពីវីរបុរសរបស់ប្រទេស ប៉ុន្តែចុះសម្រាប់ព្រះសហគមន៍កាតូលិក តើយើងឮពីអ្វី? គឺមរណសាក្សី ដែលជាសក្ខីភាពនៃការលះបង់ការពារជំនឿលុះត្រាតែចប់នៃជីវិត។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ពួកគេ គឺជាសក្ខីភាពដែលតែងតែទុកព្រះសហគមន៍ ហើយក៏ជាសាក្សីនៃសេចក្ដីពិតដែលការពារជំនឿថា ព្រះយេស៊ូព្រះអង្គមានព្រះជន្មរស់ឡើងវិញ។

# សម្ដេចបាប ហ្វ្រង់ស៊ីស្កូៈ សេចក្ដីសង្ឃឹមនៃគ្រីស្តបរិស័ទ គឺចាប់កំណើតនៅព្រឹកនៃថ្ងៃបុណ្យ ចម្លង

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា បុណ្យចម្លង គឺសំខាន់សម្រាប់គ្រីស្តបរិស័ទ ហើយ បុណ្យនេះ គឺតំណាងឲ្យការចាប់កំណើតនៃក្ដីសង្ឃឹមរបស់គ្រីស្តបរិស័ទទូទៅ។

វិទ្យុវ៉ាទីកង់ បានដកស្រង់សំដីរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលបានថ្លែងកាលពីចុងសប្ដាហ៍មុននេះថា ជំនឿរបស់យើង គឺកើតចេញមកពី ដំណឹងនៃការមានព្រះជន្មឡើងវិញ របស់ព្រះយេស៊ូ នាព្រឹកនៃថ្ងៃបុណ្យចម្លង ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងនៅក្នុងពេលជួបសវនាការ ទូទៅមួយជាមួយនឹងគ្រីស្តបរិស័ទថា ព្រះយេស៊ូផ្ទាល់គឺជាសេចក្ដីសង្ឃឹមរបស់យើង ហើយសម្រាប់ការមានព្រះជន្មឡើងវិញរបស់ទ្រង់ គឺជាព្រឹត្តិការណ៍ ដែលសម្រាប់ក្ដោបជំនឿរបស់យើងធ្វើជាមូលដ្ឋាន។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ប្រសិនបើគ្មានថ្ងៃនោះទេ គ្រីស្តសាសនាប្រហែលជា មិនអាចបង្កើតជាទស្សនវិជ្ជាសម្រាប់មនុស្ស ហើយព្រះយេស៊ូ នឹងមិនអាចក្លាយជាបុគ្គល ដ៏សំខាន់នៃសាសនាមួយនេះដែរ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ជំនឿរបស់យើង គឺឈរនៅលើមូលដ្ឋាននៃសេចក្ដីពិត ដែលកើតចេញមកពី អង្គព្រះគ្រីស្ត ដែលមានព្រះយេស៊ូជាបុត្រារបស់ទ្រង់ ហើយបានមកសង្គ្រោះមនុស្សទាំងឡាយ។

## បុរីវ៉ាទីកង់ផ្ញើសារចូលរួមពិធីបុណ្យវិសាខបូជាតាមជំនឿរបស់ព្រះពុទ្ធសាសនា

កាលពីថ្ងៃទី២២ ខែមេសា វិទ្យុវ៉ាទីកង់បានផ្សព្វផ្សាយថា បុរីវ៉ាទីកង់បានផ្ញើនូវសារលិខិត មួយច្បាប់ចូលរួមជាមួយនឹងពុទ្ធិសាសនិកនៅទូទាំងពិភពលោក នាថ្ងៃបុណ្យវិសាខបូជា។

ប្រភពដដែលបានបន្តថា សារលិខិតនេះ ត្រូវបានធ្វើ និងចុះហត្ថលេខាដោយលោកកាឌីណាល់ ជិនល្វីស តូរ៉ាន ជាប្រធាននៃក្រុមប្រឹក្សាអន្តរសាសនា និងអគ្គលេខាធិការ នៃក្រុមប្រឹក្សានេះ គឺលោកបូជាចារ្យមីហ្គែល អេនជេន អាយូសូ ហ្គីស៊ុត។

ប្រភពដដែលបានផ្សព្វផ្សាយថា សារនោះត្រូវបានផ្ញើជូនពុទ្ធិសាសនិក នៅក្រោមប្រធានបទថាគ្រីស្តសាសនិក និងពុទ្ធិសាសនិក កំពុងតែធ្វើដំណើរទាំងអស់គ្នា នៅលើផ្លូវដែលគ្មានអំពើហិង្សា។

ប្រភពដដែលបានបន្តទៀតថា សារលិខិតនោះ គឺត្រូវបានបុរីវ៉ាទីកង់សង្កត់ធ្ងន់នៅលើភាពចាំបាច់ដែលមនុស្សជាតិទាំងអស់ត្រូវតែផ្សព្វផ្សាយនូវវប្បធម៌សន្តិភាព និងគ្មានអំពើហិង្សា ដោយសារតែទស្សនៈសន្តិភាពនិងគ្មានអំពើហិង្សានេះ ហើយ ដែលជាតម្លៃដែលត្រូវបានលើកកំពស់ដោយព្រះយេស៊ូ និងព្រះពុទ្ធ។

ខ្លឹមសារនៃសារនោះ គឺបង្ហាញអំពីកំណាត់ផ្លូវដែលព្រះយេស៊ូបានដើរ ដោយមិនមាន អំពើហិង្សារហូតដល់ទីបញ្ចប់នៃជីវិតនៅលើឈើឆ្កាង ហើយមានព្រះជន្មឡើងវិញ ប៉ុន្តែនៅតែបង្រៀនសាវ័ក និងគ្រីស្តបរិស័ទទាំងអស់ កុំឲ្យប្រកាន់យកហិង្សា ដោយឡែកព្រះពុទ្ធវិញ គឺតែងតែអប់រំ និងប្រៀនប្រដៅពុទ្ធិសាសនិកឲ្យយកឈ្នះលើហិង្សាជាដើម។

## បុរីវ៉ាទីកង់ បន្តសម្ដែងការព្រួយបារម្ភអំពីស្ថានភាពនៅមជ្ឈិមបូព៌ា

តំណាងរបស់បុរីវ៉ាទីកង់ប្រចាំនៅអង្គការសហប្រជាជាតិ នៅតែបង្ហាញអំពីក្ដីបារម្ភបន្តទៀត ជុំវិញស្ថានភាពនិងស្ថានការណ៍ថ្មីៗនៅក្នុងតំបន់មជ្ឈិមបូព៌ា។

វិទ្យុវ៉ាទីកង់បានផ្សព្វផ្សាយ ការបន្តលើកឡើងអំពីការព្រួយបារម្ភរបស់ខ្លួននេះ គឺជុំវិញស្ថានភាពរវាងរដ្ឋប៉ាលេស្ទីន និងអ៊ីស្រាអែល។

តំណាងរបស់បុរីវ៉ាទីកង់ គឺជំរុញឲ្យពិភពលោក ផ្ដល់ការគាំទ្រទៅឲ្យដល់ដំណោះស្រាយរដ្ឋពីរ នៅក្នុងវិបត្តិរបស់ជនប៉ាលេស្ទីន។

នេះគឺជាជំហររបស់ លោកអគ្គអភិបាលបេណាទីតូ អូហ្សា ឯកអគ្គរាជទូតបុរីវ៉ាទីកង់ប្រចាំ នៅអង្គការសហប្រជាជាតិដែលបានថ្លែងទៅកាន់កិច្ចប្រជុំនៃក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ។

ក្រៅពីនោះ លោកក៏បានសង្កត់ធ្ងន់ទៅលើវិបត្តិនៃការប្រើប្រាស់អាវុធគីមីនៅស៊ីរី ការវាយប្រហារភេរវកម្មទៅលើគ្រីស្តបរិស័ទនៅអេស៊ីប។ល។

លោកបានសង្កត់ធ្ងន់ថា សន្តអសនៈ គឺពិតជាមានការព្រួយបារម្ភមែនជាមួយនឹងស្ថានការណ៍ថ្មីៗដែលកំពុងតែវិវត្តន៍នៅក្នុងតំបន់មជ្ឈិមបូព៌ា ខណៈដែលចំនួនជនភៀសខ្លួន បានកំពុងតែទទួលទុក្ខវេទនា ដោយសារតែសង្គ្រាម អំពើហិង្សា និងភេរវកម្ម។

# ភេរវកម្មជីហាតកំពុងតែធ្វើឲ្យនយោបាយអឺរ៉ុបមានការប្រែប្រួល




នៅព្រឹកមិញនេះសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានថ្លែងអះអាងជាថ្មី អំពីការប្ដេជ្ញាចិត្ត និងវិភាគទានរបស់កម្ពុជា ចំពោះដំណើរការស្វែងរកសន្តិភាពពិភពលោកទៅអង្គការសហប្រជាជាតិ ទោះបីជាកងទ័ពក្បាសន្តិភាពកម្ពុជាត្រូវបានសម្លាប់នៅក្នុងការវាយប្រហារមួយនៅសាធារណរដ្ឋអាហ្វ្រិកកណ្ដាល ក្នុងពេលថ្មីៗនេះ។

ថ្លែងនៅក្នុងពិធីលើកខួបទី១០ នៃអតីតយុទ្ធជនកម្ពុជា សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា កាលពីម្សិលមិញនេះ យើងបានបាត់បង់កងកម្លាំងរក្សាសន្តិភាពរបស់យើងបួននាក់ដែលកំពុងបំពេញភារកិច្ចក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ។ នៅក្នុងឱកាសនោះ សម្ដេចតេជោ ហ៊ុន សែន បានអំពាវនាវឲ្យអង្គការសហប្រជាជាតិ រៀបចំកម្លាំងឡើងវិញ ដោយសារតែកម្លាំងកម្ពុជានៅទីនោះ មិនមែនជាកម្លាំងប្រយុទ្ធឡើយ ប៉ុន្តែកម្ពុជានឹងបន្តគាំទ្រ និងផ្ដល់វិភាគទានចំពោះដំណើរការស្វែងរកសន្តិភាពដដែល។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "យើងមិនរាថយ ទេ យើងបានត្រៀមរួចហើយដើម្បី បន្តបញ្ជូនកម្លាំងរក្សាសន្តិភាពរបស់យើងទៅជួយមិត្តភក្តិបរទេសបន្ត។ យើងមិនចុះចាញ់ការរំលោភណាមួយនោះទេ។ សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា កងទ័ពកម្ពុជានឹងបញ្ជូនមន្ត្រីជាន់ខ្ពស់ទៅសើបអង្កេតករណីនេះ។ សូមបញ្ជាក់ថា កាលពីថ្ងៃទី៨ ខែឧសភា ក្រុមឧទ្ទាម Anti-Balaka បានវាយប្រហារលើកងកម្លាំងថែរក្សាសន្តិភាព នៅប្រទេសអាហ្វ្រិកកណ្ដាល ដែលបណ្ដាលឲ្យកងទ័ពមួកខៀវខ្មែរ៤នាក់ស្លាប់ របួស១នាក់ រឹងទ័ពម៉ារ៉ុក បាត់ខ្លួន១នាក់ និងរបួស៣នាក់។ បងងទ័ពខ្មែរដែលបានពលីរួមមាន អនុសេនីយ៍ទោ អ៊ឹម សំ អនុសេនីយ៍ឯក ម៉ៅ អេង ព្រិន្ទបាលទោ ស៊ាង នរិន្ទ និងព្រិន្ទបាលទោ មំ តុលា។ ជាមួយគ្នានេះ ភាគីខាងឧទ្ទាមក៏ត្រូវបានរាយការណ៍ថា ស្លាប់ចំនួន៨នាក់ផងដែរ។

ចាប់តាំងពី២០០៦ មកកម្ពុជា បានបញ្ជូនកងទ័ពមួកខៀវរបស់ខ្លួនដើម្បីចូលរួម រក្សាសន្តិភាព ក្រោមឆ័ត្ររបស់អង្គសហប្រជាជាតិ មានចំនួនសរុប ៤៥៥៥នាក់ ទៅកាន់ប្រទេស ស៊ូដង់ ស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្ដាល ប្រទេសឆាត ប្រទេសស៊ីរី ប្រទេសលីបង់ ប្រទេសម៉ាលី និង ប្រទេសស៊ីប្រ៊ីសជាដើម។

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេអភិបូជាទិវានៃការត្រាស់ហៅ នៅភ្នំពេញថ្មី ថ្ងៃទី០៧ ឧសភា ២០១៧



អត្ថបទទី១ ៖ កក ២,១៤ ក.៣៦-៤១
អត្ថបទទី២ ៖ សល ២,២០ ខ-២៥
ដំណឹងល្អ ៖ យហ ១០,១-១០

បងប្អូនជាទីស្រឡាញ់!

ជួនកាលយើងគិតថា ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាជាព្រះសហគមន៍មាន ដោយសារមានបូជាចារ្យ បងប្រុសបងស្រីច្រើនណាស់ បើធៀបជាមួយចំនួនគ្រីស្តបរិស័ទដែលមាននៅក្នុងប្រទេសយើង។ ក៏ប៉ុន្តែបូជាចារ្យខ្មែរមានតែ៩នាក់ក្រៅពីនោះ សុទ្ធតែជាសាសនទូតមកពីបរទេសដែលនៅមួយរយៈ ត្រូវត្រលប់ទៅវិញ ដើម្បីរៀនបន្ត ដើម្បីទៅបម្រើកន្លែងផ្សេងជាដើម។ ពេលខ្ញុំប្រជុំជាមួយលោកបូជាចារ្យខ្មែរទាំង៩នាក់ លោកបានសួរខ្ញុំថា "តើលោកអភិបាលទន្ទឹងរងចាំអ្វីខ្លះពីយើង?" ខ្ញុំបានឆ្លើយថា "ខ្ញុំទន្ទឹងរងចាំឲ្យជួយកសាងព្រះសហគមន៍ខ្មែរដែលចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីនេះ"។ តាមពិតយើងមិនមានគ្នាច្រើនទេ យើងធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីយើង។ ថ្ងៃនេះជាឱកាសមួយ ដើម្បីឲ្យយើងភ្ញាក់ស្មារតី ដើម្បីឲ្យយើងគិត តើព្រះជាម្ចាស់ទន្ទឹងរងចាំអ្វីខ្លះពីខ្ញុំ?។ ពេលព្រះយេស៊ូបានទេសនាលើកទីមួយនៅធម្មសាលាកាផានុមហើយ មហាជនទាំងអស់ដែលកំពុងស្តាប់គេសម្លឹងមើលព្រះយេស៊ូ ដូចគ្នាដែរយប់មិញពេលយើងបានអធិដ្ឋាននៅទីនេះ នៅពេលនោះយើងដូចជាបានសម្លឹងមើលព្រះយេស៊ូដែរ។ សម្លឹងមើលព្រះយេស៊ូដើម្បីស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ ដើម្បីចូលនៅក្នុងទំនាក់ទំនងយ៉ាងជ្រៅជាមួយព្រះយេស៊ូ ដោយសារព្រះយេស៊ូបានធ្វើដំណើរជាមួយយើងពីថ្ងៃដែលយើងទទួលការត្រាស់លើកដំបូងឲ្យស្រឡាញ់ព្រះអង្គ និងដើរតាមព្រះអង្គ។ នៅពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូលើកទីមួយ នៅពេលនោះយើងចាប់ផ្តើមស្គាល់ព្រះយេស៊ូខ្លះៗ។ អធិដ្ឋានផង ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងទទួលអគ្គសញ្ញាលើកលែងទោសផងនេះបន្តិចម្តងៗណែនាំឲ្យយើងចូលនៅក្នុងទំនាក់ទំនងជាមួយព្រះយេស៊ូដែលជាមិត្តសម្លាញ់របស់យើង។ ដូចសន្តហ្សាល់ឌីហ្វូហ្គូបានធ្វើដំណើរជាមួយព្រះយេស៊ូ និងព្រះយេស៊ូបានអោបគាត់ហើយធ្វើដំណើរជាមួយគាត់យ៉ាងជិតស្និត។

ជីវិតរបស់យើង ធ្វើដូចម្តេចដើម្បីស្គាល់ព្រះយេស៊ូថែមទៀត? ខ្ញុំសង្ឃឹមថាបងប្អូននឹងមានឱកាសច្រើនដើម្បីស្គាល់ព្រះអង្គ។ ស្គាល់ព្រះយេស៊ូថែមទៀត ដើម្បីនឹកឃើញគ្រប់ពេលវេលា ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ដំបូងយើងទទួលទឹកលើក្បាល ក្រោយមកយើងទទួលប្រេង បន្ទាប់មកយើងទទួលអាវសមានអត្ថន័យខ្លាំងណាស់ ព្រោះចាប់ពីពេលនេះតទៅយើងបំពាក់ព្រះយេស៊ូ យើងមិនអាចយកព្រះយេស៊ូចេញពីយើងបានទេ ព្រះអង្គបីដូចជាស្បែករបស់យើង។ ពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ដូចយើងបានប្រថាប់ត្រាមួយដែលមិនអាចលប់ជ្រះ នេះជាព្រះយេស៊ូដែលធ្វើដំណើរជាមួយយើង ពីពេលនោះមកយើងភ្ជាប់ជាមួយព្រះយេស៊ូ។ យើងជាគ្រីស្តបរិស័ទ ជាបរិស័ទរបស់ព្រះគ្រីស្ត ទោះបីយើងភ្លេចព្រះយេស៊ូ ទោះបីយើងនៅឆ្ងាយពីព្រះយេស៊ូ ក៏ព្រះយេស៊ូនៅជាមួយយើងដដែល។ ពេលយើងបង្កើតទំនាក់ទំនងបន្តិចម្តងៗជាមួយព្រះយេស៊ូ យើងអាចយល់ថាពិតមែនខ្ញុំជាសាវ័ករបស់ព្រះគ្រីស្ត ខ្ញុំជាមិត្តសម្លាញ់របស់ព្រះអង្គដែលភ្ជាប់ជាមួយព្រះយេស៊ូយ៉ាងជិតស្និត។ ណែនាំឲ្យយើងគិតបន្តិចម្តងៗ ខ្ញុំស្គាល់ព្រះយេស៊ូហើយ ហេតុនេះហើយទំនាក់ទំនងយ៉ាងជិតស្និតជាមួយព្រះយេស៊ូ ណែនាំឲ្យយើងគិតពិចារណាអំពីជីវិតយើង។ យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ យើងធ្វើអ្វីខ្លះដើម្បីឲ្យមិត្តភាពរបស់យើងជាមួយព្រះអង្គ ទៅជាសក្ខីភាពសម្រាប់បងប្អូនឯទៀតៗ។ ខ្ញុំធ្វើយ៉ាងណាដើម្បីដើរតាមព្រះយេស៊ូតែម្តង? ព្រះយេស៊ូជាគ្រូគង្វាលដ៏សប្បុរស ណែនាំឲ្យយើងឆ្លើយទៅព្រះអង្គ បាទ! ចាស*! ខ្ញុំចង់ធ្វើដំណើរជាមួយព្រះយេស៊ូជានិច្ច។ ដូចព្រះនាងម៉ារី ដែលបានឆ្លើយថានាងខ្ញុំជាអ្នកបម្រើសូមបានសម្រេចតាមពាក្យរបស់លោកចុះ។ ដូចលោកយ៉ូសែប ដែលជាស្វាមីរបស់ព្រះនាងម៉ារី ដែលបានឆ្លើយថា បាទខ្ញុំទទួលនាងម៉ារីជាភរិយារបស់ខ្ញុំដោយសារព្រះអង្គបានជ្រើសរើសឲ្យខ្ញុំ។ មរណសាក្សីនៅប្រទេសកម្ពុជា យើងមានទាំងលោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី និងគ្រីស្តបរិស័ទធម្មតា ដែលបានស្លាប់ ពួកគាត់ទាំងអស់មិនមែនជាមនុស្សពិសេស គេមិនបានសម្រេចចិត្តពីដើមថាយើងស្លាប់សម្រាប់ព្រះជាម្ចាស់ គេចង់រស់នៅដើម្បីបម្រើព្រះសហគមន៍។ ប៉ុន្តែនៅក្នុងកាលៈទេសៈនៃប្រវត្តិសាស្រ្តណែនាំឲ្យគេស្លាប់ដើម្បីផ្តល់សក្ខីភាពឲ្យយើង។ ពួកគាត់បានឆ្លើយពីដើមរៀងមកថា បាទ! ចាស*! ខ្ញុំចង់ធ្វើដំណើរជាមួយព្រះយេស៊ូជានិច្ច ខ្ញុំចង់ភ្ជាប់ជាមួយព្រះយេស៊ូ ដោយសារព្រះយេស៊ូណែនាំឲ្យខ្ញុំមានអំណរសប្បាយពិតប្រាកដ។ ថ្ងៃនេះយើងឃើញរបៀបព្រះយេស៊ូដែលជាគ្រូគង្វាលដ៏សប្បុរស ចៀមជាសត្វមួយដែលស្គាល់គ្រូគង្វាលរបស់វាយ៉ាងច្បាស់។ នៅអ៊ីស្រាអែលពេលយប់ អ្នកគង្វាលសត្វចៀមទាំងអស់បានប្រមូលចៀមរបស់គេមកក្នុងហ្វូងតែមួយ ដើម្បីនៅក្បែរៗគ្នាជួយការពារកុំឲ្យមានចោរលួច កុំឲ្យមានចចកមកស៊ីចៀមរបស់គេ។ ព្រឹកឡើង គេបែកគ្នាហើយអ្នកគង្វាលនីមួយៗគេមានសម្លេងពិសេសមួយដើម្បីហៅចៀមរបស់ខ្លួនឲ្យមកតាម ហើយចៀមនោះវាស្គាល់សម្លេងរបស់ម្ចាស់វាភ្លាម។ នេះជាមូលហេតុ ពេលព្រះយេស៊ូនិយាយអំពីពាក្យប្រស្នានេះមានន័យណាស់ ដោយសារព្រះយេស៊ូដ៏មានសម្លេងពិសេសមួយដើម្បីហៅយើងឲ្យដើរតាមព្រះអង្គដែរ។ ព្រះយេស៊ូបានបើកទ្វារឲ្យចៀមចូល ហើយឲ្យចៀមទាំងអស់ស្តាប់សម្លេងរបស់ព្រះអង្គ ដូច្នេះពេលព្រះយេស៊ូហៅយើង យើងមិនអាចប្រទ្បំបានទេ យើងមិនអាចដើរតាមព្យាការីផ្សេងៗបានឡើយ យើងមានតែព្រះយេស៊ូមួយព្រះអង្គគត់ដែលយើងត្រូវដើរតាម។ ចៀមស្គាល់សម្លេងព្រះយេស៊ូយ៉ាងច្បាស់ ហើយព្រះអង្គក៏ស្គាល់សម្លេងចៀមរបស់ព្រះអង្គដែរ គាត់បានហៅចៀមរបស់គាត់តាមឈ្មោះរបស់វារៀងៗខ្លួនៗ ក្រោយមកនាំចេញទៅខាងក្រៅ។ ជីវិតជាមួយព្រះយេស៊ូ គឺព្រះអង្គណែនាំឲ្យយើងចេញដើម្បីប្រកាសអំណរសប្បាយដែលយើងបានទទួលជាមួយព្រះយេស៊ូ។ នៅក្នុងព្រះសហគមន៍កម្ពុជា ជាកន្លែងមួយពិសេសដែលណែនាំឲ្យយើងអនុវត្តព្រះបន្ទូលនេះ។ ពេលខ្ញុំចាប់ផ្តើមបេសកកម្មជាមួយលោកលី នៅឆ្នាំ២០០១ យើងមានគ្រីស្តបរិស័ទតែម្នាក់គត់ រហូតមកដល់សព្វថ្ងៃយើងមានប្រហែល៥០០នាក់ហើយ។ នេះដោយសារយើងចេញទៅប្រកាសដំណឹងល្អពីភូមិមួយទៅភូមិមួយ ពីចំការទៀងទៅគិរីវង់ ពីគិរីវង់នៅកោះស្លា ពីកោះស្លាទៅសន្តប៉ូល ពីសន្តប៉ូលទៅព្រៃកប្បាស់ ពីព្រៃកប្បាស់ទៅត្រពាំងក្រញូង ពីត្រពាំងក្រញូងទៅកំពង់អំពិល ពីកំពង់អំពិលទៅទីរួមខេត្តតាកែវ។ តាមកន្លែងនីមួយៗ យើងត្រូវការចេញយើងមិនអាចជាប់នៅកន្លែងមួយ ផ្ទុយទៅវិញព្រះយេស៊ូណែនាំឲ្យយើងចេញទៅខាងក្រៅ។ ជួនកាលមនុស្សយើងភ័យ យើងខ្លាចទៅជួបមនុស្សថ្មី ទីកន្លែងថ្មី យើងភ័យខ្លាចទៅបង្កើតទំនាក់ទំនងជាមួយមនុស្សដែលយើងមិនដែលស្គាល់សោះ ប៉ុន្តែលុះគាត់បញ្ចេញចៀមចេញពីក្រោលអស់ហើយ គាត់ដើរនាំមុខវា ហើយវាដើរតាមក្រោយគាត់ព្រោះវាស្តាប់សម្លេងគាត់។ យើងមានព្រះយេស៊ូនៅខាងមុខ ព្រះយេស៊ូធ្វើដំណើរជាមួយយើង ព្រះអង្គនៅជាមួយយើង យើងមិនត្រូវខ្លាចអ្វីទេ ព្រោះព្រះអង្គជួនកាលនៅខាងមុខ ជួនកាលនៅកណ្តាល ជួនកាលនៅខាងក្រោយដើម្បីជំរុញឲ្យយើងទៅ។ យើងត្រូវការគិតអំពីជីវិតរបស់យើង យើងធ្វើដូចម្តេចដើម្បីឲ្យជីវិតរបស់យើងជាគ្រីស្តបរិស័ទ ជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ចេញពីកន្លែងផ្ទាល់ខ្លួនទៅផ្តល់សក្ខីភាពដើម្បីណែនាំឲ្យមនុស្សផ្សេងៗអាចទទួលសំណាសប្បាយនៃដំណឹងល្អ ដោយដឹងថា "ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យគេមានជីវិតពេញបរិបូរណ៍"។ ទោះបីព្រះសហគមន៍របស់យើងតូចក៏ដោយ យើងខិតខំរស់នៅក្នុងអំណរសប្បាយ ដោយសារយើងដឹងថាព្រះយេស៊ូចង់ឲ្យយើងមានជីវិតយ៉ាងបរិបូរណ៍។ ថ្ងៃនេះយើងបន្តអធិដ្ឋាន ដោយសួរខ្លួនឯងថា តើខ្ញុំអាចធ្វើដូចម្តេចដើម្បីបម្រើបងប្អូនឯទៀតៗ ឲ្យគេបានទទួលជីវិតពីព្រះយេស៊ូ? តើខ្ញុំធ្វើដូចម្តេចដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះយេស៊ូដែលខ្ញុំបានទទួលនៅក្នុងជីវិតរបស់ខ្ញុំ អាចទៅជាសេចក្តីស្រឡាញ់មួយពិសេសសម្រាប់បងប្អូនឯទៀតៗដែរ? តើខ្ញុំធ្វើដូចម្តេច ដើម្បីឲ្យជីវិតរបស់ខ្ញុំទៅជាជីវិតមួយដែលណែនាំឲ្យពិភពរបស់ខ្ញុំទៅជាពិភពថ្មី?

ថ្ងៃនេះយើងអធិដ្ឋានសម្រាប់យុវជនយុវនារីទាំងអស់ យើងអធិដ្ឋានសម្រាប់លោកបូជាចារ្យ បងប្រុសបងស្រី បងប្អូនគ្រីស្តបរិស័ទទាំងអស់ ដែលបានយកចិត្តទុកដាក់បម្រើព្រះសហគមន៍នៅក្នុងសេចក្តីស្រឡាញ់ពីមួយថ្ងៃទីមួយថ្ងៃ ដោយសង្ឃឹមថាយើងនឹងមានគ្រូគង្វាលដ៏សប្បុរសយ៉ាងច្រើនថែមទៀត ដោយសារចំការរបស់យើងធំណាស់ យើងធ្វើដូចម្តេចដើម្បីឲ្យចំការរបស់យើងមានទាំងកម្មករ មានទាំងអ្នកច្រូត ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតពិសេសសម្រាប់មនុស្សទាំងឡាយ ដោយដឹងថាពិតមែនយើងជាមនុស្សសាមញ្ញធម្មតា ប៉ុន្តែយើងជាមនុស្សពិសេសអស្ចារ្យ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើង ព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់ចាត់យើងឲ្យទៅជានិច្ច។ អាម៉ែន។



រាត្រីបុណ្យចំចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍ បាត់ដំបង និងសៀមរាប





សំណាក់ធម៌ប្រចាំឆ្នាំនៃបូជាចារ្យព្រះសហគមន៍នៅកម្ពុជា នៅព្រះសហគមន៍កាតូលិកសន្តមីកាលអែល ក្រុងព្រះសីហនុ ពីថ្ងៃទី១៥-២០ ខែឧសភា ឆ្នាំ២០១៧.

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍កាតូលិក



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នៅព្រះសហគមន៍កាតូលិក ប៊ូស្រា



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍កាតូលិក គុលលើ



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹម ចម្ការទៀង



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍កាតូលិក សន្តសិលា និងសន្តប៉ូល



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នៅព្រះសហគមន៍កាតូលិក ត្រែងត្រយឹង



រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍ផ្សារតូច



# ល្បាតព្រៃដើម្បីកូនចៅជំនាន់ក្រោយ

អ៊ីវ៉ាន់សំពីងសំពោងចងដឹកតាមម៉ូតូជាច្រើនគ្រឿង ដែលក្នុងនោះមានស្បៀងអាហារ សាំង អង្រឹង និងតង់ ក្រុមសហគមន៍ការពារព្រៃឈើបានរៀបចំជាមួយគ្នាដើម្បីចុះល្បាតក្នុងព្រៃ។ ពួកគាត់ធ្វើបែបនេះជារឿយៗអស់រយៈពេល១០ឆ្នាំ មកហើយគឺដើម្បីប្រយោជន៍រួមរបស់កូនចៅជំនាន់ក្រោយ។

លោកសុខ អេង អាយុ៣០ឆ្នាំ មកពីសហគមន៍ព្រៃឡង់ បានឲ្យដឹងថា "ការពារព្រៃឈើទុកឲ្យកូនចៅជំនាន់ក្រោយបានឃើញ"។ លោកអេង បានចុះល្បាតជាមួយក្រុមសហគមន៍បានបីដង។ លោកបានប្រាប់ថា លោកធ្លាប់មិនធ្លាប់មានការគំរាមកំហែងពីសំណាក់អាជ្ញាធរនៅក្នុងភូមិស្រុកទេ តែអាជ្ញាធរហាក់មិនចង់ឲ្យពួកគាត់ចូលរួមសកម្មភាពនេះ។ លោកសុខ អេង "អត់ទេ ដូចជាមិនសូវសហការជាមួយសហគមន៍ដូចថាប្រជាជនទេមានតែខឹងថែម (ហើយ) ទាក់ទាញយើងមិនឲ្យមកចូលរួមជាមួយសហគមន៍។

ក្នុងការដើរល្បាតរយៈពេល៣យប់ គឺចាប់ពីថ្ងៃទី២៤ ដល់២៧ ឧសភា ក្រុមសហគមន៍ដែលមានសមាជិកជាង ២០ នាក់ សមាជិកក្រុមអង្គការជេស្វីតសឺវីស ចំនួន៧នាក់ និងមានមន្ត្រីបរិស្ថាន២នាក់ ដោយប្រើប្រាស់ម៉ូតូ បើកឆ្លងកាត់ព្រៃជាច្រើនម៉ោងបន្តពីមួយកន្លែងទៅមួយកន្លែង។ អមសងខាងផ្លូវ ខ្មោចដើមឈើធំមួយចំនួនត្រូវបានរំលំនិងច្រៀកជាចម្រៀកៗដែលមានមុខកាត់យ៉ាងហោចណាស់១ម៉ែតគូប។

លោកវ៉ង់ សាន អាយុ៤៧ឆ្នាំជាប្រធានក្រុមសហគមន៍ព្រៃឈើក្បាលខ្លាឲ្យដឹងថា "ពេលចុះមកម្ដងៗដេកពីយប់ បីយប់អីទើបទៅវិញ។ យើងតាមដានសភាពការបើស្ងាត់យើងក៏អត់ចុះដែរ។ ជួនកាលអត់មានជួបទេ ជួនកាលជួប។ បើសព្វថ្ងៃ ជួបអ្នកកាប់ក្រាក់ កាប់អីតិចតួចទេ ហើយចំការក៏វាលួចដែរតែធ្វើតិចៗ គឺពង្រីកតិចៗ។ បើសួររកមុខម្ចាស់រកអត់ឃើញ។ ជួនកាលមួយថ្ងៃវារំលំមួយដើមពីរដើមអីចឹងទៅ ឬបីបួនដប់ថ្ងៃមួយដើមអីចឹង"។

បើតាមប្រសាសន៍របស់លោកប្រធានសហគមន៍ក្បាលខ្លារូបនេះ សកម្មភាពកាប់បំផ្លាញព្រៃឈើបានកាត់បន្ថយហើយក្នុងពេលបច្ចុប្បន្ននៅតាមតំបន់ដែលក្រុមការងាររបស់លោកបានចុះល្បាតជាញឹកញាប់។ លោក វ៉ង់ សាន និយាយថា "ពួកខ្ញុំចុះជាញឹកញាប់ដែរវាអន់ថយហើយ។ វានៅបាន ៨០ភាគរយដែរ(ចំពោះ)ដី(ព្រៃ)សហគមន៍"។

ក្នុងពេលចុះល្បាតព្រៃក៏មានការលំបាកខ្លះៗជាមួយក្រុមជនល្មើសទាំងនោះដែរ លោកវ៉ង់ សានឲ្យដឹងថា "អត់ដែលមានតតាំងអីជាមួយគ្នាទេតែមានកាំបិតពូថៅជាមួយគ្នាដែរ។ កាលពីដើមពួកខ្ញុំ(មាន) គ្នាតិចមែនទែន ៤ ឬ៥នាក់ គេ៣០ទៅ៤០នាក់តែយើងដោះស្រាយ(ឲ្យ)គេដើរចេញវិញបាន ដោយមិនប្រើអំពើហិង្សា"។

តាមប្រសាសន៍របស់លោកអ៊ុក អៀន ជាមន្ត្រីផ្នែកបរិស្ថានបានឲ្យដឹងថា ចាប់តាំងពីខែកក្កដាឆ្នាំ២០១៦ ដល់ខែមេសាឆ្នាំ២០១៧នេះ ប្រជាសហគមន៍និងមន្ត្រីបរិស្ថានខេត្តកំពង់ធំបានបញ្ជូនខ្លួនជនល្មើសចំនួន១០នាក់ទៅកាន់ពន្ធនាគារ។ តាមរបាយការណ៍លោកបានឲ្យដឹងថា ជនល្មើសដែលចូលទៅកាប់ឈើទាំងនោះគឺនៅស្រុកឆ្ងាយពីតំបន់ព្រៃឡង់ និងជាប្រជាជនធម្មតា។

លោកបានបន្តទៀតថា ក្នុងច្បាប់របស់ប្រទេសកម្ពុជា គឺយើងគិតលើបទល្មើសជាក់ស្ដែង។ "បុគ្គល ឬជនណាដែលយើងចាប់បាននៅក្នុងហ្នឹង ពេលហ្នឹងដែលយើងឃើញគាត់កំពុងប្រព្រឹត្តបទល្មើស គឺត្រូវមានទោស ពី១ឆ្នាំ ទៅ៥ឆ្នាំតាមច្បាប់"។

បច្ចុប្បន្ននេះ ក្រុមល្បាតព្រៃនៃសហគមន៍ក្បាលខ្លានេះ មានការចូលរួមពីភូមិចំនួន២ គឺភូមិក្បាលខ្លា និងភូមិស្រែចង់ ដែលមានសមាជិកចំនួនជាង៥០០នាក់ មានបញ្ជីឈ្មោះនៅសាលាឃុំ។ ការចុះល្បាតនេះ គឺសហគមន៍ដោយផ្ទាល់បានចំណាយនូវកំលាំង និងសម្ភារផ្ទាល់ខ្លួនដើម្បីធ្វើសកម្មភាពនេះ។ ការចុះល្បាតនៅចុងខែមេសា សហគមន៍នេះ បានចាប់បានរណាអាឈើចំនួន៣គ្រឿងបញ្ជូនឲ្យមន្ត្រីបរិស្ថានទុក និងបានណែនាំដល់អ្នករកជំនៀឈើក្នុងតំបន់អភិរក្សមិនឲ្យចូលមកបំផ្លាញជាថ្មីម្ដងទៀត។ *កញ្ញា*



